សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# មុខងារសារការីនៃព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវ ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ដល់ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៤


| | |
|---|---|
| ស្រាវជ្រាវដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ **ខេង ម៉ុនឡេង** | **គង់ សុភ័ក្ត្រ** |



| | |
|---|---|
| ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ | ឆ្នាំចូលសិក្សា ២០១០ |
| ជំនាន់ទី១៤ | ឆ្នាំសរសេរសារណា ២០១៤ |

# សេចក្តីថ្លែងអំណរគុណ

សារណាបញ្ចប់ការសិក្សាមួយនេះ បានសម្រេចជាផ្លែផ្កាឡើងដូចពេលនេះគឺដោយសារមានការជួយគាំទ្រ លើកទឹកចិត្ត និងណែនាំពីនាក់ជុំវិញខ្លួនរបស់ខ្ញុំបាទទាំងអស់ ដែលពួកគាត់ទាំងអស់គ្នាបានយកចិត្តទុកដាក់ ផ្តល់ជាកម្លាំងចិត្តដល់រូបខ្ញុំបាទ ក្នុងការតាក់តែងសារណានេះឡើង។

ជាបឋមខ្ញុំបាទសូមលំអោនកាយវាចារចិត្ត និងសម្តែងនូវកត្តាញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតជូនចំពោះលោក ឪពុក **ឈុំ ខេន** អ្នកម្តាយ **ម៉ិច ចន្ថា** ដែលបានផ្តល់កំណើតដល់រូបកូន ហើយបានចិញ្ចឹមបីបាច់ថែរក្សា និងផ្តល់សេចក្តីស្រលាញ់ និងអប់រំទូន្មានកូនដោយព្រហ្មវិហារធម៌ ព្រម-ទាំងជួយទំនុកបំរុង និងធ្វើពលីកម្មគ្រប់បែបយ៉ាងដល់រូបកូន រហូតដល់កូនបានបញ្ចប់ការសិក្សាដោយទទួលបានចំណេះដឹងដ៏មានសារៈប្រយោជន៍យ៉ាងក្រៃលែង ដែលមិនអាចកាត់ថ្លៃបានដូចពេលនេះ។

បន្ទាប់មក ខ្ញុំបាទក៏សូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រីសាស្ត្រចារ្យ ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលោកទាំងអស់បានខិតខំអស់ពីកម្លាំងកាយចិត្ត ក្នុងការបង្ហាត់បង្រៀន ផ្តល់ចំណេះដឹង និងចំណេះធ្វើដល់រូបខ្ញុំបាទនាពេលកន្លងមកនេះ។ ជាពិសេសខ្ញុំបាទសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅដល់លោក **សាស្ត្រាចារ្យ គង់ សុផ័ក្ត្រ** ដែលបានចំណាយពេលវេលាដ៏មរមារញឹក និងមានតម្លៃដែលមិនអាចកាត់ថ្លៃបានរបស់លោក ក្នុងការផ្តល់នូវអានុសាសន៍ល្អៗ ចង្អុលពីទីកន្លែងស្រាវជ្រាវ និងបង្ករលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដែលជាវិភាគទានដ៏សំខាន់ ក្នុងការរៀបចំចងក្រងសារណាមួយនេះឲ្យចេញជាសមិទ្ធផលឡើង រហូតទទួលបានជោគជ័យជាស្ថាពរដូចពេលនេះ។

មួយវិញទៀតខ្ញុំបាទក៏សូមអរគុណ ចំពោះការជួយផ្តល់ជាគំនិតល្អៗរបស់មិត្តភក្តិ សិស្សច្បងនិងនាក់ដែលរាប់អានខ្ញុំទាំងអស់ ដែលតែងតែជួយដោយផ្តល់ជាគំនិត ក៏ដូចជាការលើកទឹកចិត្តដល់រូបខ្ញុំបាទក្នុងការធ្វើសារណានេះ។

## អារម្ភកថា

សារណាដែលមានឈ្មោះថា "**មុខងារសារការីនៃព្រះរាជាណាចក្រកម្ពុជា**" ដែលមិត្តអ្នកអានកំពុងកាន់ក្នុងដៃនេះ គឺជាសារណាមួយដែលបានធ្វើឡើង ដោយការខិតខំប្រឹងប្រែងរបស់ខ្ញុំបាទអស់រយៈពេលជិត៦ខែ។ បុព្វហេតុដែលនាំឲ្យខ្ញុំជ្រើសរើសប្រធានបទនេះ មកបក-ស្រាយគឺ ព្រោះតែវិជ្ជាជីវៈសារការីនេះ ជាវិជ្ជាជីវៈមួយដែលកម្រនឹងមានអ្នកបានដឹង និងស្គាល់អំពីវិជ្ជាជីវៈនេះណាស់ សូម្បីតែអ្នកអនុវត្តការងារច្បាប់ និងនិស្សិតច្បាប់ផងនោះ។ ខ្ញុំសង្ឃឹមថា អត្ថបទដ៏តិចតួចស្តួចស្តើងមួយនេះ អាចបង្ហាញអំពីមុខងារដ៏កម្រមានអ្នកដឹងមួយនេះ ឲ្យអ្នកបានយល់អំពីមុខងាររបស់សារការី ។

ការសិក្សាស្រាវជ្រាវ ក៏ដូចជាការចងក្រងដ៏ពិកបាក ដើម្បីទទួលបាននៅសារណាមួយនេះ គឺពិតជាធ្វើឲ្យខ្ញុំទទួលបាននៅចំនេះដឹង និងបទពិសោធន៍ជាច្រើនទាក់ទងទៅនឹង ការគិតនូវគំនិតដើម្បីច្នៃប្រឌិតនៅអ្វីមួយដែថ្មីសម្រាប់ខ្លួនខ្ញុំផ្ទាល់ ហើយក៏ដើម្បីជាផលប្រយោជន៍សម្រាប់អ្នកសិក្សាដ៏ទៃទៀតដែរ ជាពិសេស គឺនិស្សិតនិងអ្នកស្រាវជ្រាវជំនាន់ក្រោយៗទៀត សម្រាប់យកវាទុកជាការវិភាគមួយក្នុងការស្រាវជ្រាវនៅអត្ថបទ ឬ បញ្ហាគតិយុត្តនានាដែលទាក់ទងនឹងមុខងាររបស់សារកា-រី។

ប្រទេសកម្ពុជាយើង គឺជាប្រទេសដែលយកច្បាប់ ដើម្បីគ្រប់គ្រង់នៅរាល់ស្ថានភាពទាំង-អស់។ ដូច្នេះប្រទេសកម្ពុជាយើង គឺត្រូវការជាចាំបាច់នៅវត្តមានសារការីដើម្បីរក្សាស្ថានភាពដែលទាក់ទង និងបញ្ហាគតិយុត្តនានា ដូចជា ការបង្កើត កិច្ចសន្យា ការផ្ទេរកម្មសិទ្ធិ នឹង ស្ថានភាមួយចំនួនទៀតជាច្រើន ដែលតម្រូវឲ្យមានមុខងារសារការីក្នុងការរក្សាស្ថានភាពទាំងនោះ ប្រព្រឹត្តទៅដោយរលូន និងបញ្ចៀសការប្តឹងផ្តល់ទៅស្ថាប័នតុលាការ។ ទាំងអស់នេះគឺជាសារៈប្រយោជន៍ ដ៏-ចាំបាច់ ដែលមិនអាចខ្វះបាននៅមុខងារ និងតួនាទីរបស់សារការី។

ដោយសារសារណានេះជាស្នាដៃដំបូងរបស់ខ្ញុំ គឺប្រាកដជាមានការខ្វះខាតនៅពាក្យពេចន៍ឃ្លោងឃ្លារ អក្សរាវិរុទ្ធ និង អត្ថន័យមួយចំនួន ជាមិនខាននោះទេ ដែលនឹងធ្វើឲ្យអ្នកទាំងអស់គ្នាកើតឡើងនៅចង្ងល់ នៅពេលអានសារណាមួយនេះ ហេតុដូច្នេះហើយ នៅរាល់កំហុសដែលកើតឡើងដោយអចេតនានៅក្នុងសារណារបស់ខ្ញុំនោះ ខ្ញុំបាទសូមអភ័យទោសទុកជាមុន ហើយខ្ញុំបាទសូមស្វាគមន៍ និងរង់ចាំនូវការរិះគន់ដើម្បីស្តាបនានៅរាល់កំហុសទាំងនោះ ដោយសេចក្តីរីករាយបំផុត។

# មាតិកា

ទំព័រ

សេចក្តីថ្លែងអំណរគុណ ........ i

អារម្ភកថា ........ ii

សេចក្តីផ្តើម ........ ១

## ជំពូកទី១ សញ្ញាណទូទៅនៃមុខងាររបស់សារការី

១.១ ប្រវត្តិនិងការកកើតនៃមុខងារ ........ ៣

១.១.១ ការកកើតវិជ្ជាជីវៈសារការី ........ ៣

១.១. ២ ប្រវត្តិនៃការកកើតមុខងារសារការី ........ ៨

១.១.២.១ ព្រះរាជក្រមលេខ ៩១០ ន.ស ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ ........ ៨

១.១.២.២ អនុក្រឹត្យលេខ ៥០៥ អនក្រ.តត ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០១ ........ ៩

១.១.២.៣ អនុក្រឹត្យលេខ ១៩៤ អនក្រ.បក ចុះ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៨ ........ ១១

១.១.២.៤ ក្រោយក្រមរដ្ឋប្បវេណី ២០០៧ ចូលជាធរមាន ........ ១១

១.២ លក្ខខណ្ឌដើម្បីបានទទួលមុខងារជាសារការី ........ ១៦

១.២.១ ការទទួលបានមុខងារសារការីដោយអនុក្រឹត្យ ........ ១៧

១.២.២ ការតែងតាំងដោយប្រកាសនៅមន្ត្រីទទួលបន្ទុកកិច្ចការសារការី ........ ១៨

១.២.៣ សារការីកំពុងបណ្តុះបណ្តាល ........ ២៣

ក បណ្តុះបណ្តាលបឋម ៖ ........ ២៩

ក.១ ត្រីមាសសិក្សាអំពីនីតិទូទៅ ........ ២៩

ក.២ ត្រីមាសសិក្សាអំពីនីតិគ្រួសារ ........ ២៩

ក.៣ ត្រីមាសសិក្សាអំពីនីតិអចលនទ្រព្យ ........ ២៥
ក.៤ ត្រីមាសសិក្សាអំពីនីតិជំនួញ ........ ២៥
១.២.៣.២ កម្មសិក្សានិងការជួបជុំផ្តោះប្តូរបទពិសោធន៍ ........ ២៦
ក. កម្មសិក្សានិងការបណ្តុះបណ្តាលឆ្លាស់ ........ ២៦
ខ. ការជួបជុំផ្តោះប្តូរបទពិសោធន៍ ........ ២៦

## ជំពូកទី២ ការអនុវត្តមុខងារ និងតួនាទីរបស់សារការី

២.១ មុខងារ និង តួនាទីរបស់សារការី ........ ២៩
២.១.១ មុខងារដែលមានបញ្ញត្តិក្នុងច្បាប់ ........ ២៩
២.១.២ លិខិតរបស់សារការី ........ ៣១
២.១.២.១ វត្តមានរបស់គូភាគីហត្ថលេខី ........ ៣៣
២.១.២.២ វត្តមានរបស់សារការី ........ ៣៤
២.១.២.៣ វត្តមានសាក្សី ........ ៣៥
២.១.២.៤ ការចុះហត្ថលេខារបស់សារការី ........ ៣៥
២.១.២.៥ ការប្រថាប់ត្រារបស់សារការី ........ ៣៦
២.២ ការមិនអាចអនុវត្តបាននៃមុខងារសារការី ........ ៣៧
២.២.១ ការបែងចែកមិនច្បាស់លាស់ជាមួយមន្ត្រីអនុវត្តផ្សេងទៀត ........ ៣៩
២.២.១.១ រដ្ឋបាលសុរិយោដី ........ ៣៩
២.២.១.២ រដ្ឋបាលមូលដ្ឋាន ........ ៤០
២.២.២ ការអនុវត្តជាក់ស្តែង ........ ៤១
២.២.២.១ ទំហំនៃការងាររបស់សារការី ........ ៤២

២.២.២.២ ការផ្សព្វផ្សាយ ........................................................................................ ៤២

២.២.២.៣ ការមិនអាចអនុវត្តបាននៃលិខិតរបស់សារការី...................................... ៤២

២.២.២.៤ តម្លៃសេវារបស់សារការី........................................................................ ៤២

សេចក្ដីសន្និដ្ឋាន..................................................................................................... ៤៣

អនុសាសន៍..............................................................................................................៤៥

ឯកសារយោង ..........................................................................................................៤៨

ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

ប្រត្តិបត្តិការនានាលើអចលនវត្ថុ ជាវិស័យអាទិភាពមួយ ក្នុងចំណោមវិស័យសំខាន់ផ្សេងៗទៀតដែលរាជរដ្ឋាភិបាលបានកំណត់ ជាវិស័យចម្បងក្នុងការជំរុញ កំណើនសេដ្ឋកិច្ចនៅកម្ពុជា។ ការលក់ ការដូរ សន្តិកម្ម ប្រទានកម្ម និងការធ្វើអំណោយជាប្រត្តិបត្តិការលើអចលនវត្ថុ ដ៏ចម្បងបំផុតដែលគេតែងតែជួបប្រទះជាញឹកញាប់ និងជាប្រចាំ។ ចំនុចរួមនៃប្រត្តិបត្តិការទាំងនេះ គឺការនាំឲ្យកើតមាននូវលទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុ ពីបុគ្គលមួយទៅបុគ្គលមួយទៀត។ ផ្អែកតាមទិដ្ឋភាពគតិយុត្តកម្ពុជានាពេលបច្ចុប្បន្ន នៅពេលដែលមានការកើតឡើង នូវលទ្ធកម្មសិទ្ធិលើអចលនវត្ថុនោះគេតែងតែនិយាយអំពី ទម្រង់យថាភូត ឬរូបមន្តយថាភូត។ ជាក់ស្តែងទាក់ទងនឹងការលក់អចលនវត្ថុមាត្រា៦៥ នៃច្បាប់ភូមិបាលឆ្នាំ២០០១ បានចែងថា "ការផ្ទេរកម្មសិទ្ធិ មិនអាចជំទាស់ពីតតិយជនបាន លុះត្រាតែកិច្ចសន្យាលក់អចលនវត្ថុត្រូវបានធ្វើឡើង ជាលាយលក្ខណ៍អក្សរតាម **ទម្រង់យថាភូតធ្វើដោយអាជ្ញាធរមានសមត្ថកិច្ច** ហើយត្រូវបានចុះបញ្ជីនៅក្រសួងសុរិយោដី"។ តើលិខិតយថាភូតជាអ្វី? ហើយអាជ្ញាធរមានសមត្ថិច្ចជាអ្នកណា?

បើយើងទៅមើលបញ្ញត្តិនានា ដែលទាក់ទងទៅនឹងការធ្វើលិខិតយថាភូត យើងនឹងដឹងភ្លាមថាអ្នកណាដែលមានតួនាទី ក្នុងការធ្វើលិខិតយថាភូត គឺមន្រ្តីសាធារណៈដែលទទួលបាន ប្រត្តិភូ-កម្មអំណាចពីរាជរដ្ឋាភិបាលពោល គឺ **សារការី** តែម្តង។ មុខងាររបស់ **សារការី** ត្រូវបានប្រសូត្រចេញជារូបរាងឡើង តាំងពីក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩៦៧មកម្លេះ ក៏ប៉ុន្តែក្រមនេះមិនបានចែងឲ្យបានពិស្តារទាក់ទងនឹងមុខងារ និង តួនាទីរបស់សារការីឲ្យបានលម្អិតនោះទេ។ បន្ទាប់មក នាឆ្នាំ១៩៥៤ ទើបគេសង្កេតឃើញថា មុខងារនិងតួនាទីរបស់សារការីត្រូវបានលម្អិត និងពណ៌នាយ៉ាច្បាស់លាស់ជាងអ្វីដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩៦៧ ដែលមុខងារទាំងនោះមានចែងក្នុង ព្រះរាជក្រមលេខ៩១០ ន.ស ឆ្នាំ១៩៥៤។ មាត្រា១ ចំណុចទីមួយ នៃព្រះរាជក្រមលេខ ៩១០ ន.ស ឆ្នាំ១៩៥៤ នេះបានបញ្ញត្តិ អំពីមុខងាររបស់សារការីថា "សារការី ជាមន្រ្តីសារធារណៈដែលតែងតាំងឡើងតាម ព្រះរាជក្រឹត្យនៃរាជរដ្ឋាភិបាល ដោយមានវត្ថុបំណង៖ ទទួល និងធ្វើតាមត្រូវការនូវលិខិត ឬកិច្ចសន្យាទាំងឡាយ ដែលគូសញ្ញាត្រូវធ្វើឲ្យមាន ឬចូលចិត្តឲ្យមានចារិកជាពេញលក្ខណៈ តាមផ្លូវច្បាប់ ដែលតែងតែមានដល់លិខិតរបស់រាជការកាន់អំណាចសាធារណៈ"។ ដោយឡែក បើ-យោងតាមអត្ថន័យនៃសន្ទានុក្រមនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានឲ្យនិយមន័យនៃ **សារការី** ថាជាមន្រ្តីសាធារណៈដែលមានមុខងារធ្វើលិខិតយថាភូតបញ្ជាក់អំពីលក្ខណៈពិតត្រឹមត្រូវ

ធានារ៉ាប់រងអំពីកាលបរិច្ឆេទ តម្កល់ រក្សាទុក ចេញសេចក្តីចម្លងយថាភូត នៃលិខិតទាំងឡាយដែលត្រូវឲ្យមានការបញ្ជាក់។ យោងទៅតាមការឲ្យនិយមន័យតាមសន្ធានុក្រមរដ្ឋប្បវេណី និងមាត្រា១ ចំនុចទី១ នៃព្រះរាជក្រម លេខ៩១០ ន.ស ឆ្នាំ១៩៥៤ នេះយើងអាចនិយាយជារួមបានថា **សារការី** គឺជាមន្ត្រីសាធារណៈដែលមានសមត្ថកិច្ចក្នុងការធ្វើ លិខិតយថាភូត បញ្ជាក់ពីភាពត្រឹមត្រូវនៃលិខិត តម្កល់ រក្សាទុក ចេញសេចក្តីចម្លងទាំងឡាយឲ្យមានយថាភូតភាព និង បំពេញនូវមុខងាររបស់ខ្លួន ក្នុងការ **ផ្តល់ចារិកលក្ខណៈពេញលក្ខណៈតាមផ្លូវច្បាប់ ដល់លិខិតឬកិច្ចសន្យា** ទាំងឡាយដែលច្បាប់បានអនុញ្ញាត។ មិនត្រឹមតែព្រះរាជក្រមលេខ ៩១០ ន.ស ឆ្នាំ១៩៥៤ នេះទេដែលនិយាយពីមុខងារនិងតួនាទីរបស់សារការី គឺមានបទប្បញ្ញត្តិជាច្រើនទៀតដែលបានលើកឡើងពីមុខងាររបស់សារការីនេះ។ តើសារការីមានមុខងារអ្វីខ្លះ? តើសារការីអនុវត្តការងាររបស់ខ្លួនយ៉ាងដូចម្តេចដែរ? នេះគឺជាចំណោទបញ្ហាមួយដែលយើងទាំងអស់គ្នាចង់ដឹង និងចង់យល់ទាំងអស់គ្នា។

ដោយមុខងារសារការី គឺជាចម្ងល់មួយដែលអ្នកទាំងអស់គ្នាចង់ដឹង និងគួតែដឹងជាពិសេសនិស្សិតច្បាប់និងអ្នកអនុវត្តច្បាប់អំពីមុខងារសារការីនេះ សារណារបស់ខ្ញុំនឹងធ្វើការបកស្រាយ នូវ-រាល់ចម្ងល់ទាំងអស់នេះ។ ហើយសារណានេះត្រូវបានបែងចែកជាពីរជំពូកសំខាន់ ដូចខាងក្រោមនេះ ៖

- ជំពូកទី១ ៖ សញ្ញាណទូទៅមុខងារសារការី
- ជំពូកទី២ ៖ ការអនុវត្តមុខងារ និង និងតួនាទីរបស់សារការី

# ជំពូកទី១ សញ្ញាណទូទៅនៃមុខងាររបស់សារការី

## ១.១ ប្រវត្តិនិងការកកើតនៃមុខងារ

### ១.១.១ ការកកើតវិជ្ជាជីវៈសារការី

សារការី គឺជាវិជ្ជាជីវៈមួយដែលមានជាយូរយារណាស់មក ហើយមិនត្រឹមតែកម្ពុជាដែលបានទទួលស្គាល់វិជ្ជាជីវៈនេះ ប៉ុន្តែក៏មានប្រទេសជាច្រើនទៀតដែលបានយកវិជ្ជាជីវៈសារការីនេះយកទៅអនុវត្ត ដើម្បីថែរក្សាស្ថានភាពគតិយុត្តរបស់ប្រទេសពួកគេឲ្យមានស្ថេរភាព។

ប្រវត្តិសាស្ត្រនៃស្ថាប័នសារការី បានបញ្ចូលលាយឡំជាមួយនិងប្រវត្តិសាស្ត្រមនុស្សជាតិតាំងពីយូរយារណាស់មកហើយ។ តាមពិតទៅ ការវិវត្តិវិជ្ជាជីវៈសារការីបានចាប់ផ្តើមជាមួយ នឹងឱភាសកម្ម[១](ការធ្វើឲ្យទូទៅ) នៃអក្សរ។ ហើយយើងទាំងអស់គ្នាសុទ្ធតែបានដឹងថា ប្រសិនបើគ្មានភស្តុតាងមកបញ្ជាក់នោះទេ យើងនឹងមានការលំបាក ក្នុងការការពារនូវផលប្រយោជន៍ស្របច្បាប់។ ដូច្នេះ នៅក្នុងស្រទាប់ប្រជាជនគ្រប់ជាតិសាសន៍កាលពីសម័យបុរាណ មាននអ្នកចម្លង លិខិត និងកិច្ចសន្យា ហើយបំពេញមុខនាទីជាមន្រ្តីសារធារណៈដែលទទួលបន្ទុក កិច្ចព្រមព្រៀង ឬកិច្ចសន្យាទាំងឡាយរបស់បុគ្គលឯកជន ហើយនឹងបំពេញតួនាទីជាមន្ត្រីសាធារណៈនៃភស្តុតាង[២]។

ជាពិសេសនៅក្នុងទីក្រុងរ៉ូម មន្ត្រីសាធារណៈខាងសារការីបានកាន់កាប់ (កំណត់សម្គាល់) កិច្ចសន្យាដែលត្រូវបានធ្វើឡើងនៅចំពោះមុខសាក្សីមួយចំនួន។ ពាក្យថា**សារការី** នេះមកពីពាក្យថា **សម្គាល់**។

កាលពីមជ្ឈឹមសម័យនា ចន្លោះសតវត្សទី៥ និង ទី១៥ ដោយមានការវិវត្តន៍វិស័យពាណិជ្ជកម្ម និងជំនួញ ជីវភាពគតិយុត្តកាន់តែមានភាពចាំបាច់ខ្លាំងឡើងជាលំដាប់ ដែលត្រូវរៀបចំឡើងឲ្យស្ថិតនៅលើមូលដ្ឋានមួយដ៏ជឿជាក់ ហើយជាធម្មតាសារការីបានក្លាយជាសកម្មជន សម្រាប់ការអភិវឌ្ឍនីតិ និងសម្រាប់ការរៀបចំជីវភាពសង្គម នៅលើសកម្មភាពទាំងនោះ។

នៅពេលមានការចាប់កំណើតជាថ្មី កាលពីឆ្នាំ១៥៣៩ ហ្វ្រង់ស្វ័ទី១ បានប្រកាសឲ្យប្រើបញ្ញត្តិមួយ ដែលដាក់ជាភាសាបារាំងឲ្យប្រើប្រាស់ជាផ្លូវការ នៅក្នុងរាល់លិខិតទាំងអស់។ លិខិតនោះត្រូវតែអានចំពោះមុខគូភាគី នៅមុនពេលដែលគូភាគី ទាំងឡាយចុះហត្ថលេខា ហើយសារការីក៏ចុះហត្ថលេខាខ្លួនឯងផងដែរ ព្រមទាំងបញ្ជាក់លិខិតនេះដើម្បីឲ្យមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់។

---

[១] ឱភាសកម្ម មានន័យថា ការធ្វើឲ្យទៅជាលក្ខណៈទូទៅ។

[២] សៀវភៅ ស្តីពីសន្និសិទស្តីពីមុខងារសារការីតាមបែបប្រទេសបារាំង ថ្ងៃទី ១៧-១៨ ខែកុម្ភៈ ឆ្នាំ២០០៤ ទំព័រទី៧។

នៅសម័យកាលដ៏ចលាចល នៃបដិវត្តន៍ស្ថាប័នសារការីបានពុះពារជំនះរយៈកាលដ៏សែនឈឺចាប់ខ្លោចផ្សាបំផុតនៃប្រវត្តិសាស្ត្ររបស់ខ្លួន។ នៅពេលក្រោយបន្តិចមក អ្នកធ្វើរបាយការណ៍ នៃច្បាប់វ៉ង់តូស ស្តីពីការរៀបចំមុខងារសារការីបានរំលឹកឡើងថា "ការរៀបចំមុខងារសារការី គឺជាកម្មវត្ថុមួយ ក្នុងចំណោមកម្មវត្ថុដ៏មានសារៈសំខាន់បំផុត ប្រចាំនីតិកាលការរៀបចំនេះជាប់ទាក់ទងនឹងអត្ថប្រយោជន៍របស់ប្រជារដ្ឋគ្រប់រូប"។ ហើយរាល់ការពិចារណាទាំងនេះបានសម្រេចជោគជ័យដោយខ្ពង់ខ្ពស់បំផុត ព្រោះដោយតែការអនុម័តច្បាប់ចុះថ្ងៃទី១៧ ខែមិនា ឆ្នាំ១៨០៣ ដែលបានបង្កើតជាក្រមសម្រាប់សារការី ហើយដែលអ្នកនាំពាក្យរបស់ក្រុមប្រឹក្សារដ្ឋវីល បានផ្តល់នូវនិយមន័យដ៏អស្ចារ្យនៃភាពចាំបាច់របស់មុខងារសារការី។ ទាំងអស់នេះ គឺជាប្រវត្តិរបស់សារការីដែលមានអាយុកាលជាងមួយសហស្សវត្សមកនេះ។

បើយើងក្រឡេកមើល ប្រវត្តិនៃវិជ្ជាជីវៈសារការីនៃព្រះរាជាណាចក្រកម្ពុជាយើងវិញ វិជ្ជាជីវៈ-សារការី បានចាប់ផ្តើមអនុវត្តតាំងពីដើមសតវត្សទី២០មកម្លេះ។វិជ្ជាជីវៈនេះកាលដំបូងបានប្រព្រឹត្តទៅក្រោមឥទ្ធិពលនៃច្បាប់បារាំង ពីព្រោះនាពេលនោះប្រទេសកម្ពុជាបានស្ថិតនៅក្រោយ អាណា-និគមបារាំង។ តែនៅពេលនោះ ព្រះរាជាណាចក្រកម្ពុជាមានសារការីមិនច្រើនទេ ប្រហែលជា ពីរ បីនាក់ប៉ុណ្ណោះ ពីព្រោះនៅសម័យនោះការងារសារការី ពុំទាន់ជ្រួតជ្រាបដល់ប្រជាពលរដ្ឋភាគច្រើននោះទេ ដោយហេតុថាការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋ នៅមានកម្រិតទាបនៅឡើយ ហើយពួកគេក៏មិនសូវជាយកចិត្តទុកដាក់ទៅលើបញ្ហានេះដែរ ហើយភាគច្រើនអ្នកដែលស្គាល់មុខងារ និងការងាររបស់សារការីនេះមានតែអ្នកជំនួញ នឹងអ្នកនៅទីផ្សារមួយចំនួនតូចប៉ុណ្ណោះ។ កន្លែងដែលសារការីធ្វើការគេប្រែជាភាសាខ្មែរយើងថា **មន្ទីរ**។ នៅសម័យនោះសារការីខ្មែរយើងដំបូងគេបង្អស់ គឺលោកសារការី **អ៊ឹង អ៊ី** ដែលមានមន្ទីរសារការីនៅភ្នំពេញ។ រាល់កិច្ចការដែលគាត់បានធ្វើ គឺធ្វើជាភាសាបារាំង លាយនិងភាសាខ្មែរ។ បន្ទាប់មកគឺលោកសារការី **ចេង ហេង** ក្រោយមកទៀត គឺលោកសារការី **ប៉ុក ធួន។** ប៉ុន្តែ នៅមុខក្រសួងសារការីនៅតែអាចយកបទប្បញ្ញត្តិ នៃដេក្រេចុះថ្ងៃ-ទី២៤ ខែសីហា គ.ស១៩២១ និងអត្ថបទនៃច្បាប់បារាំងទាំងអស់ ដែលមុនបានប្រកាសឲ្យប្រើជាត្រឹមត្រូវនៅឥណ្ឌូចិនមកប្រើដដែល ប្រសិនបើបញ្ញត្តិនោះមិនផ្ទុយពីព្រះរាជក្រមលេខ៩១០នោះទេ[៣]។

បន្ទាប់ពីមានការប្រគល់សមត្ថកិច្ច មកឲ្យតុលាការកម្ពុជាយើងវិញ ដោយប្រទេសបារាំង នាថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៥៣ ដោយពិធីសារមួយ ព្រះរាជក្រមមួយបានសរសេរជាភាសាខ្មែរផង និង

[៣] អាំង អេងថុង វិជ្ជាជីវៈសារការីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១២ ទំព័រ ទី១៧។

បកប្រែជាភាសារបារាំងផង បានត្រូវលាយព្រះហត្ថលេខា ដោយព្រះអង្គម្ចាស់ជីវិតលើត្បូង នៅថ្ងៃទី០៤ ខែវិច្ឆិកា គ.ស១៩៥៤ ដែលមានលេខ ៩១០ន.ស។ នៅក្នុងព្រះរាជក្រមនោះ មានតែមន្ទីសារ-ការីតែមួយប៉ុណ្ណោះដែលត្រូវបានបង្កើតឡើង ដើម្បីប្រកបវិជ្ជាជីវៈនេះនៅក្នុងប្រទេសទាំងមូល។ ប៉ុន្តែនៅក្នុងព្រះរាជក្រមនេះនៅក្នុងមាត្រា៦ បានបញ្ញត្តិថា ត្រូវបង្កើតមន្ទីសារការីមួយនៅភ្នំពេញ ដែលអ្នកកាន់កាប់ត្រូវមានសមត្ថកិច្ច ដើម្បីចាត់ការមុខក្រសួងពេញអាណាខេត្ត នៃព្រះរាជាណាចក្រកម្ពុជា។ តាមសេចក្តីស្នើសុំនៃរដ្ឋមន្ត្រីក្រសួងយុត្តិធមិ គណៈរដ្ឋមន្ត្រីអាចបន្ថែមព្រះរាជក្រឹត្យតាមតម្រូវការ ឲ្យមន្ទីសារការីមានចំនួនឡើងដល់ទៅ០៥ នៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល។ ព្រះរាជក្រឹត្យដែលបង្កើតមន្ទីជាថ្មី ត្រូវខណ្ឌព្រំដែននាទីសមត្ថកិច្ចនៃមន្ទីនោះផង។ រហូតដល់ឆ្នាំ ១៩៦៥ រដ្ឋាភិបាលបានបង្កើតព្រះរាជក្រឹត្យមួយទៀតលេខ ១២៩ ប.រ ដែលទ្រង់លាយព្រះហត្ថលេខាដោយសម្តេចព្រះប្រមុខរដ្ឋ ចុះថ្ងៃទី១៨ ខែមិនា គ.ស ១៩៦៥ កម្រិតឲ្យមន្ទីសារការីចំនួន ០៥ កន្លែងទៀត[៤] ដូចការគ្រោងទុក គឺ៖

- **មន្ទីសារការីទី២** មាននៅរាជធានីភ្នំពេញ មានសមត្ថកិច្ចលើដែនដីក្នុងរាជធានីភ្នំពេញ និងខេត្តកណ្តាល។
- **មន្ទីសារការីទី៣** នៅខេត្តបាត់ដំបង សម្រាប់ព្រំដែននៃដែនដីខេត្តបាត់ដំបង កំពង់ឆ្នាំង កំពង់ធំ ព្រះវិហារ ពោធិ៍សាត់ និង ខេត្តសៀមរាប។
- **មន្ទីសារការីទី៤** នៅខេត្តកំពត សម្រាប់ព្រំដែននៃដែនដីខេត្តកំពត កោះកុង កំពង់ស្ពឺ តាកែវ ព្រមទាំងមណ្ឌលស្វយ័តភាពនៃក្រុងកែប បូកគោ គីរីរម្យ និងក្រុងព្រះសីហនុ។
- **មន្ទីសារការីទី៥** នៅខេត្តកំពង់ចាម សម្រាប់ព្រំដែននៃដែនដីខេត្តកំពង់ចាម ក្រចេះ មណ្ឌលគីរី ព្រៃវែង រតនគីរី ស្ទឹងត្រែង និង ខេត្តស្វាយរៀង។

ស្របតាមប្រការ៣ នៃព្រះរាជក្រម លេខ ៩១០ ន.ស ឆ្នាំ១៩៥៤ នេះសារការីទាំងឡាយនឹងអាចធ្វើសារលិខិតជាសាធារណៈបានក្នុងមុខនាទី ក្នុងព្រំដែននៃដែនដីដែលបានបញ្ជាក់ដូចខាងលើនេះស្រាប់បើពុំនោះទេសារការីនោះ និងត្រូវចោទប្រកាន់តាមវិធានវិន័យ ដែលបញ្ញត្តិក្នុងមាត្រា១៤ នៃព្រះរាជក្រមលេខ ៩១០ន.ស ចុះថ្ងៃទី៤ ខែវិច្ឆិកា គ.ស១៩៥៤។ ប៉ុន្តែ ព្រះរាជក្រមលេខ ៩១០ន .ស ឆ្នាំ១៩៥៤ នេះត្រូវបានផ្អាកដំណើរការពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ដោយសារប្រទេសយើងស្ថិតក្នុងរបបខ្មែរក្រហម។ ក្រោយពីរួចផុតពីរបបនេះប្រល័យពូជសាសន៍នេះ រហូតមកដល់សព្វថ្ងៃយើងពុំទាន់ឃើញមានបទដ្ឋានគតិយុត្តណា ចែងនិរាករណ៍ព្រះរាជក្រមនេះឡើយ តែទោះជាយ៉ាង

[៤] អាំង អេងថុង វិជ្ជាជីវៈសារការីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១២ ទំព័រ ទី១៨។

ណាក៏ដោយ ព្រះរាជក្រមនេះពុំត្រូវបានយកមកប្រើប្រាស់ ឬធ្វើជាបទដ្ឋានយោងក្នុងការតាក់តែងបទប្បញ្ញត្តិថ្មីៗ ក្រោយៗទៀតដែលទាក់ទងនឹងមុខងារសារការីនោះឡើយ។ ហេតុដូច្នេះ យើងអាចសន្និដ្ឋានបានថា ព្រះរាជក្រមនេះត្រូវបាននិរាករណ៍ដោយតុណ្ហីភាព គឺតាមរយៈការមិនយកមកប្រើប្រាស់។ បន្ទាប់មកទៀត ដោយមានតម្រូវការជាចាំបាច់ក្នុងការអនុវត្តន៍មុខងារសារការី រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតស្ថាប័នសារការីមួយ តាមអនុក្រឹត្យលេខ ៥០៥ អនក្រ.តត ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០១។ លោក **ប៉ែនសុន សម័យ** ត្រូវបានតែងតាំងដោយអនុក្រឹត្យនេះក្នុងភាពចាំបាច់ និងជា-បន្ទាន់នូវមុខងារបន្ថែមជា **មេធាវីសារការី** នៃព្រះរាជាណាចក្រកម្ពុជា ការតែងតាំងនេះត្រូវបានកំណត់ដោយរាជរដ្ឋាភិបាល ជាមន្ត្រីសាធារណៈទទួលនូវមុខងារសាធារណៈ ឲ្យប្រកបវិជ្ជាជីវៈសេរីជាសារការី តម្រូវឲ្យមានទីតាំងត្រឹមត្រូវ ដើម្បីធ្វើជាមន្ទីសារការី ដែលត្រូវមានទ្រព្យធន និង មូលនិធិគ្រប់គ្រាន់សម្រាប់ធានា តំកល់បំណុលរដ្ឋ និងសងការខូចខាតដល់អតិថិជន ។ ដោយមុខងារសារការី ជាមុខងារមួយដែលស្ថិតក្នុងវិស័យច្បាប់ មុខងារនេះក៏ត្រូវបានចាប់អារម្មណ៍យ៉ាងខ្លាំង ក្នុង-ពពួកមេធាវី រហូតនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០២ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានទទួលញ្ញត្តិរបស់សមាជិក សមាជិកាមេធាវីរបស់ខ្លួន ដោយមានចុះហត្ថលេខាចំនួន១០៥នាក់ ដើម្បីស្នើដល់ក្រុមប្រឹក្សាគណៈមេធាវី បើកមហាសន្និបាតវិសាមញ្ញមួយពិសេស ស្តីអំពីមុខនាទីមេធាវីសារការីតាមអនុក្រឹត្យ ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែម ជាសារការីដល់មេធាវីនៃគណៈមេធាវី នៃព្រះ-រាជាណាចក្រកម្ពុជា លេខ ៥០៥ អនក្រ.ត.ត ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០១ ។ មហាសន្និបាតវិសាមញ្ញនេះ បានប្រព្រឹត្តទៅនៅសណ្ឋាគារអាំងទែរកង់ទីណង់តាល់។ ក្រោមមកទៀត សារការីពីររូបទៀតក៏ត្រូវបានតែងតាំង នាឆ្នាំ២០០៨ ដោយរាជរដ្ឋាភិបាលក៏បានចេញអនុក្រឹត្យលេខ ១៤៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ ដែលជាអនុក្រឹត្យដំបូងបង្អស់ដែលប្រកាសទទួលស្គាល់មន្ទីសារការីដែលមានឈ្មោះថា "**មន្ទីសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា**"[៥]។ ហើយនិងមានបញ្ញត្តិមួយចំនួនទៀតទាក់ទង នឹងការតែងតាំង មន្ត្រីទទួលបន្ទុកសារការី ដូចជា ប្រកាសរបស់ក្រសួងយុត្តិធមិ លេខ ៤៧ កយ.ប្រក/១២ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១២ ។ ប្រកាសមួយទៀតទាក់ទងនឹងការកំណត់ មន្ត្រីទទួលបន្ទុកសារការីរបស់ក្រសួងយុត្តិធមិដដែល លេខ ៧២ កយ.ប្រក / ១២ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២ ដដែល ហើយធ្វើឲ្យប្រកាសលេខ ៤៧ ត្រូវបាននិរករណ៍

[៥] មាត្រា១នៃអនុក្រឹត្យនេះបានចែងថាៈ ត្រូវបានទទួលស្គាល់ការបង្កើតមន្ទីសារការីដែលមានឈ្មោះថា មន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា (HBS Notary public of the kingdom of Cambodia) សរសេរកាត់ជាភាសាខ្មែរ "អ.ប.អ.ស" សរសេរកាត់ជាភាសាខ្មែរ ជាភាសាអង់គ្លេស"H.B.S.N"។

ដោយប្រកាសនេះ[៦]។ ហើយការវិវត្តិចុងក្រោយ នៃវិជ្ជាជីវៈសារការីនៃព្រះរាជាណាចក្រកម្ពុជាយើងនេះ គឺការបង្កើតសាលាភូមិន្ទ សារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ដោយអនុក្រឹត្យលេខ ១១៧ អនក្រ.បកចុះ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨ និងការចាប់ផ្តើមបណ្តុះបណ្តាល សិស្សសារការីជំនាន់ទី១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈសារការី ដែលសិស្សសារការីទាំង១៥នាក់ កំពុងបណ្តុះបណ្តាលសព្វថ្ងៃនេះត្រូវបាន ជ្រើសរើសដោយការប្រលងប្រជែង ដើម្បីឲ្យចូលបំរើការងារក្នុងវិជ្ជាជីវៈសារការីនេះ ដែលបានតែងតាំងដោយប្រកាសលេខ ១៧ ប្រក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣។

ដោយសារតែប្រទេសកម្ពុជាធ្លាប់ស្ថិតនៅក្រោមអាណានិគមបារាំង ដូច្នេះប្រព័ន្ធសារការីកម្ពុជាក៏ត្រូវយកតាមប្រព័ន្ធច្បាប់ស៊ីវិល ( Civil-law system ) ដែលជាប្រភពរបស់ច្បាប់រ៉ូម៉ាំង (Roman Law) ។ ហើយប្រព័ន្ធច្បាប់រ៉ូម៉ាំងនេះ មានភាពស៊ីជម្រៅជាងប្រព័ន្ធអង់គ្លេស ( Common-Law system ) (ដែលមានប្រភពមកពីប្រទេស អង់គ្លេស និង អាមេរិក ច្បាប់នេះអនុវត្តទៅតាមករណីយុត្តិសាស្ត្ររបស់តុលាការ ដែលធ្លាប់មានពីមុនមក)។

ចំពោះគោលការណ៍នៃប្រព័ន្ធច្បាប់ស៊ីវិលវិញ រាល់លិខិតស្នាមទាំងអស់ត្រូវតែ សរសេរជាលាយលក្ខណអក្សរ។ ច្បាប់នេះ ត្រូវបានគាក់តែងតាមទម្រង់នីត្យានុកូលដើម្បីការពារ និងធានារាប់រងផលប្រយោជន៍ស្របតាមច្បាប់របស់រដ្ឋ និងប្រជាពលរដ្ឋទូទៅទាក់ទងនឹងកិច្ចសន្យា។ល។

មន្ទីសារការីជាស្ថាប័នសាធារណៈ ដែលទទួលបាននូវអំណាចសាធារណៈពីរាជរដ្ឋាភិបាលក្នុងការធ្វើនីត្យានុកូលកម្ម ធ្វើលេខាចារឹក ប្រថាប់ត្រា លើឯកសារទាំងឡាយ ក្នុងគោលដៅកាត់បន្ថយនូវចំណុចវិវាទ ក្នុងរឿងក្តីតាមផ្លូវតុលាការ ដូចជារឿង ដីធ្លី កិច្ចសន្យា លក់ ទិញ បញ្ចាំ ជួលផ្ទេរកម្មសិទ្ធិ និងកិច្ចសន្យាជំនួញផ្សេងៗទៀត។

ប្រវត្តិ និងការវិវត្តន៍នៃវិជ្ជាជីវៈសារការី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានបកស្រាយខាងលើនេះសបញ្ជាក់ឲ្យឃើញថា វិជ្ជាជីវៈសារការីបានកើតឡើងតាំងពីយូរយារណាស់មកហើយពោលគឺចាប់តាំងពីឆ្នាំ១៩៥៤ មកម្លេះ ហើយបន្តរហូតមកដល់បច្ចុប្បន្ន។ ហេតុអ្វីបានជាព្រះរាជាណាចក្រកម្ពុជាចាំបាច់មានវិជ្ជាជីវៈសារការីនេះ? តើមុខងារសារការីមានអ្វីខ្លះ? តើប្រវត្តិនៃការកកើតមុខងារសារការីមានចាប់តាំងពីពេលណាមក(**១.១.២ប្រវត្តិនៃការកកើតមុខងារសារការី**)? ហើយថាតើមុខងារសារការីមានការវិវត្តិយ៉ាងណាដែរ តាំងពីមានវិជ្ជាជីវៈសារការីនេះ រហូតមកដល់បច្ចុប្បន្ន?

[៦] ប្រកាសលេខ៤៧ កយ.ប្រក/១២ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១០១២ត្រូវរបស់ក្រសួងយុត្តិធម៌ត្រូវទុកជានិរាករណ៍

## ១.១.២ ប្រវត្តិនៃការកកើតមុខងារសារការី

### ១.១.២.១ ព្រះរាជក្រមលេខ៩១០ ន.ស ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ ១៩៥៤

ដូចបានរៀបរាប់ខាងលើខ្លះហើយថាវិជ្ជាជីវៈសារការី គឺបានអនុវត្តនៅក្នុងប្រទេសយើងជាយូរណាស់មកហើយ គឺតាំងពីដើមសតវត្សទី២០មកម្លេះ ប៉ុន្តែពេលនោះយើងអនុវត្តនៅក្រោមឥទ្ធិពលនៃច្បាប់បារាំង។ ហើយបន្ទាប់មកទៀត ក៏មានការចែងពីមុខងារសារការីផងដែរនៅក្នុងក្រមរដ្ឋវេណីចាស់ឆ្នាំ១៩៦៧ ប៉ុន្តែក្រមនេះពុំបានចែងឲ្យបានច្បាស់លាស់ទាក់ទងទៅនិងសារការីនោះទេ។ បន្ទាប់មក នាឆ្នាំ១៩៥៤ ទើបយើងសង្កេតឃើញថាមុខងារ និង តួនាទីរបស់សារការី ត្រូវបានលម្អិត និងពណ៌នាច្បាស់លាស់ជាងអ្វីដែលមានចែងនៅក្នុង ក្រមរដ្ឋវេណីចាស់ដែលមុខងារទាំងនោះមានចែងនៅក្នុងព្រះរាជក្រម លេខ ៩១០ ន.ស ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤។

មាត្រា ១ នៃព្រះរាជក្រមលេខ ៩១០ ន.ស ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ បានបញ្ញត្តិអំពីមុខងាររបស់សារការីថា៖

"សារការីជាមន្ត្រីសាធារណៈ ដែលតាំងឡើងតាមព្រះរាជក្រឹត្យនៃរាជរដ្ឋាភិបាល ដោយមានវត្ថុបំណង" ៖

១. ទទួល និងធ្វើតាមលិខិត ឬកិច្ចសន្យាទាំងឡាយដែលគូសញ្ញា ត្រូវធ្វើឲ្យមាន ឬចូលចិត្តឲ្យមានចារិកជាលក្ខណៈតាមផ្លូវច្បាប់ ដែលតែងតែមានដល់ លិខិតរបស់រាជការកាន់អំណាចសាធារណៈ។

២. ធ្វើបញ្ជាក់កាវិយបរិច្ឆេទនៃលិខិតនេះ ទទួលរក្សាលិខិតនេះទុក និងចេញឲ្យសេចក្តីដើម ឬសេចក្តីចម្លងលិខិតនេះ។

៣.ករណីកិច្ចរបស់សារការី គឺបំភ្លឺ ឲ្យដំណឹង និងទូន្មានគូសញ្ញា ដើម្បីពិនិត្យឲ្យដឹងថាសេចក្តីកត់ចុះក្នុងលិខិតទាំងនោះត្រឹមត្រូវតាមការពិត"។

យើងទាំងអស់គ្នាឃើញថា មាត្រា១ ចំណុចទី១ នៃព្រះរាជក្រមនេះបានគូសបញ្ជាក់ អំពីមុខងារដ៏ចម្បងជាងគេរបស់សារការី ដោយបានផ្តល់សមត្ថកិច្ច ឲ្យសារការីបំពេញមុខងាររបស់ខ្លួនក្នុងការ**ផ្តល់ចារិកពេញលក្ខណៈតាមផ្លូវច្បាប់ដល់លិខិត ឬកិច្ចសន្យាទាំងឡាយ** ពោលគឺលិខិតរបស់សារការីអាចយកមកអនុវត្តបានយ៉ាងពេញលេញ ព្រោះលិខិតនេះមានតម្លៃពេញលេញតាមច្បាប់។ ដោយផ្អែកលើ លក្ខណៈនេះយើងឃើញថា ការផ្តល់ចារិកជាលក្ខណៈតាមផ្លូវច្បាប់ដល់លិខិត ឬកិច្ចសន្យាទាំងឡាយ គឺមានខ្លឹមសារ ថាជាការផ្តល់យថាភូតភាពលើលិខិតទាំងនោះ។ ព្រះរាជក្រមឆ្នាំ១៩៥៤នេះ បានធ្វើការវិវត្តន៍ពាក្យពេចន៍គតិយុត្ត នៃក្រមរដ្ឋវេណីចាស់ ដោយមិនប្រើពាក្យ

"លិខិតយថាភូត" ឬខ្លឹមសារដែលស្រដៀងនឹងការផ្ដល់យថាភូតភាពលើលិខិតនោះទេ ប៉ុន្តែបែរជាប្រើពាក្យដូចដែលបានលើកឡើងដោយអក្សរដិតខាងលើទៅវិញ។ លើសពីនេះទៅទៀតមាត្រា៣នៃព្រះរាជក្រមនេះ បានធ្វើការបញ្ជាក់បង្ហាញ អំពីមុខងាររបស់សារការីបន្ថែមទៀតថា៖

" ប៉ុន្តែទៅមុខទៀត មានតែសារការីទេ ដែលអាច**បញ្ជាក់តាមទម្រង់មុខការរបស់ខ្លួន** នូវលិខិតគ្រប់ប្រភេទ បើកាលណាលិខិតនោះមានចុះទឹកប្រាក់ចំនួនស្មើ នឹងលើសពី ២០០.០០០រៀល"។

យើងពិនិត្យឃើញថា មាត្រា៣នេះ មិនបានប្រើប្រាស់ខ្លឹមសារ ដែលមានក្នុងន័យថាផ្ដល់យថាភូតភាពលើលិខិតនោះទេ តែបានប្រើពាក្យបញ្ជាក់ជំនួសវិញ។ ទោះជាយ៉ាងណាក៏ដោយ យើងអាចធ្វើការសរុបមុខងាររបស់សារការីនៅក្នុងព្រះរាជក្រមនេះដោយខ្លីថា សារការីមានមុខងារ៖

- ផ្ដល់យថាភូតភាព ទៅលើលិខិតទាំងឡាយ ជាពិសេសគឺរាល់លិខិតដែលមានចុះទឹកប្រាក់ចាប់ពី ២០០.០០០រៀល ឡើងទៅ
- ធ្វើការបញ្ជាក់លិខិត ទទួលរក្សាលិខិត ឬចេញសេចក្ដីដើម ឬសេចក្ដីចម្លង ឲ្យគូភាគីនិង
- មានករណីកិច្ចធ្វើការ បំភ្លឺ ផ្ដល់មតិយោបល់ ឬលើកទស្សនៈយល់ឃើញរបស់ខ្លួនទៅគូភាគីនៃកិច្ចសន្យា។

ផ្អែកតាមការលើកឡើងខាងលើ អំពីមុខងារសារការី មានចង្ងល់មួយលើកឡើងថា តើព្រះ-រាជក្រមនេះលេខ ៩១០ ន.ស ឆ្នាំ១៩៥៤ នេះ នៅតែមានអានុភាពអនុវត្ត មកដល់ពេលបច្ចុប្បន្នដែរ ឬ យ៉ាងណា? យើងមើលឃើញថា ព្រះរាជក្រមនេះ ត្រូវបានបង្កើត តាំងពីឆ្នាំ១៩៥៤ មកម្លេះ។ តែព្រះរាជក្រមនេះ ត្រូវបានឈប់អនុវត្តក្នុងកំឡុងពេលដែល ប្រទេសយើងបានមានសង្គ្រាមស៊ីវិលពោលគឺកំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ក្រោយពីរួចផុតពីរបបប្រល័យពូជសាសន៍ រហូតមកដល់សព្វថ្ងៃនេះ យើងពុំទាន់ឃើញមាន បទដ្ឋានគតិយុត្តណាចែង និរាករណ៍ព្រះរាជក្រមនេះឡើយ តែទោះបីជាយ៉ាងណាក៏ដោយ ព្រះរាជក្រមនេះពុំដែលត្រូវបានយកមកប្រើប្រាស់ ឬធ្វើជាបទដ្ឋានយោង ក្នុងការតាក់តែងបទបញ្ញត្តិថ្មីៗ ក្រោយៗទៀតដែលទាក់ទង នឹងមុខងារសារការីនោះឡើយ។ ហេតុដូច្នេះ យើងអាចសន្និដ្ឋានបានថា ព្រះរាជក្រមនេះត្រូវបាននិរាករណ៍ដោយតុណ្ហីភាព ហើយយើងក៏អាចនិយាយបានថា វាត្រូវបាននិរាករណ៍ដោយការមិនយកមកប្រើប្រាស់។

### ១.១.២.២ អនុក្រឹត្យលេខ ៥០៥ អនក្រ.គត ចុះថ្ងៃទី ៨ ខែធ្នូ ឆ្នាំ២០០១

អនុក្រឹត្យលេខ ៥០៥ អនក្រ.គត ស្ដីពីការផ្ដល់សមត្ថកិច្ចបន្ថែម ជាសារការីដល់ មេធាវី នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១នេះ ក៏បានផ្ដល់សញ្ញាណច្បាប់ដែលទាក់ទង នឹងការផ្ដល់យថាភូតភាពដែរ។ ថ្វីត្បិតតែអនុក្រឹត្យនេះ ជាប្រភេទអនុក្រឹត្យដែល

តែងតាំងបុគ្គលក៏ពិតមែន ក៏បានឆ្លុះបញ្ចាំងអំពីមុខងារ និងសមត្ថកិច្ចរបស់សារការីក្នុងការផ្តល់យថាភូតភាព ដល់ប្រត្តិបត្តិការគតិយុត្តនានា ជាពិសេសក្នុងវិស័យអចលនវត្ថុ។ មាត្រា ៣ នៃអនុក្រឹត្យនេះផ្តល់សមត្ថកិច្ចការងារទូទៅក្នុងវិស័យអចលនវត្ថុ ដល់មេធាវីសារការីដូចជា៖

- ទទួលនិងធ្វើ ឬចារឹកបញ្ជាក់ និង ប្រថាប់ត្រានូវ លិខិតគតិយុត្ត ឬកិច្ចសន្យាទាំងឡាយដើម្បីជាបន្ទាល់ពេញលក្ខណៈតាមផ្លូវច្បាប់ ដែលតែងតែមានលិខិតរបស់ រាជការសាធារណៈធ្វើការបញ្ជាក់លើ ការបរិច្ឆេទ ទទួលតម្កល់ទុកឯកសារ និងចេញឲ្យនៅសេចក្តីដើម ឬសេចក្តីចម្លងនៃលិខិត ឬកិច្ចសន្យាទាំងឡាយនោះតាមមុខការ និង
- កិច្ចការនេះត្រូវត្រួតពិនិត្យអានឲ្យអស់សេចក្តី និងចុះហត្ថលេខានៃគូភាគីនៅចំពោះមុខទើបសារការីចុះហត្ថលេខា ប្រថាប់ត្រា ចារឹក នាពេលនោះជាចុងក្រោយ។

យើងពិនិត្យឃើញថា ចំណុចទី១ បានគូសបញ្ជាក់អំពីមុខងាររបស់មេធាវីសារការី ដែលមានសមត្ថកិច្ចក្នុងការចារឹកបញ្ជាក់ និងប្រថាប់ត្រាលើលិខិតគតិយុត្ត ឬកិច្ចសន្យានានា ដើម្បីឲ្យឯកសារទាំងនោះក្លាយជាឯកសារ ដែលមានលក្ខណៈ តាមផ្លូវច្បាប់។

ទន្ទឹមនឹងនោះ ព្រះរាជក្រមលេខ ៩១០ន.ស ឆ្នាំ១៩៥៤ បានដាក់កំហិតថា បុគ្គលដែលមានសម្បទាជាសារការី ត្រូវបំពេញមុខងាររបស់ខ្លួន ដោយមានជាមន្ទីសារការី[៣]។ ការដាក់កំហិតនេះ គឺដោយសារតែសារការីជាមន្ត្រីសារធារណៈ ដែលទទួលបានប្រតិភូកម្មអំណាចពីរដ្ឋ ក្នុងការផ្តល់យថាភូតភាពលើលិខិត និងកិច្ចសន្យាមួយចំនួន។ ហេតុដូច្នេះ ការបំពេញមុខងារនេះ សារការីត្រូវបំពេញមុខងារក្នុងនាមរដ្ឋ មិនមែនក្នុងនាមជាឯកជននោះទេ ដែលចាំបាច់ត្រូវបំពេញមុខការដោយមានស្ថាប័នគ្រប់គ្រង់មួយយ៉ាងជាក់លាក់ ដែលតម្រូវឲ្យមានជាមន្ទីសារការី។ ការកំហិតនេះ ក៏ទាក់ទងផងដែរនិងការទទួលខុសត្រូវរបស់សារការី។ យើងឃើញថា ប្រសិនបើសារការីបំពេញ មុខងារក្នុងនាមខ្លួនឯងផ្ទាល់ ដោយមិនមែនជាមន្ទីច្បាស់លាស់ ការទទួលខុសត្រូវគឺកើតមានចំពោះតែលក្ខណៈនៃបុគ្គលសារការីនោះតែប៉ុណ្ណោះ ផ្ទុយទៅវិញ ប្រសិនបើការបំពេញមុខងារគឺស្ថិតនៅក្រោមរូបភាពជាមន្ទីសារការី ដែលបញ្ញត្តិដោយព្រះរាជក្រមនេះ ឃើញថាការទទួលខុសត្រូវគឺមានរូបភាពជាការទទួលខុសត្រូវរួមក្រោមទិដ្ឋភាពជាស្ថាប័នតែម្តង។

[៣] មាត្រា ៦ នៃរាជក្រមលេខ ៩១០ ឆ្នាំ ១៩៥៤ ន.ស ឆ្នាំ១៩៥៤ បញ្ញាត្តិថា៖លក្ខណៈត្រូវតាំងឲ្យកាន់មុខក្រសួងជាសារការី៖ត្រូវបង្កើតនៅភ្នំពេញ មន្ទីសារការីមួយ ដែលអ្នកកាន់កាប់ត្រូវមានសមត្ថកិច្ច ដើម្បីចាត់ការមុខក្រសួងពេញអាណាខេត្តព្រះរាជាណាចក្រកម្ពុជា។[...]

### ១.១.២.៣ អនុក្រឹត្យលេខ ១៤៤ អនក្រ.បក ចុះ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០៨

អនុក្រឹត្យលេខ ៥០៥ ខាងលើ គឺជាអនុក្រឹត្យដែលមានចារឹកលក្ខណៈជា អនុក្រឹត្យប្រកាសតែងតាំងបុគ្គលតែប៉ុណ្ណោះ មិនមែនជាអនុក្រឹត្យប្រកាសបង្កើតស្ថាប័ន ឬ អង្គភាពអ្វីនោះទេ។ ដោយឡែក អនុក្រឹត្យ១៤៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៨ គឺជាអនុក្រឹត្យដំបូងទី១ដែលប្រកាសទទួលស្គាល់មន្ទីសារការី ដែលមានឈ្មោះថា " **មន្ទីសារការី អេច ប៊ី អេស នៃព្រះរាណាចក្រកម្ពុជា** "។ អនុក្រឹត្យនេះបានផ្តល់តួនាទី និងភារកិច្ចរបស់សារការីតាមរយៈមាត្រា៣ ដូចខាង ក្រោមះ

- ទទួលធ្វើរាល់លិខិតស្នាមគតិយុត្ត ឬកិច្ចសន្យាទាំងឡាយដែលរូបវន្តបុគ្គល ឬនីតិបុគ្គលនៃនីតិឯកជន ឬ នីតិបុគ្គលនៃនីតិសាធារណៈមានកាតព្វកិច្ច ផ្តល់យថាភូតភាពតាមច្បាប់កំណត់ ឬមានបំណងផ្តល់យថាភូតភាពដោយខ្លួនឯង
- ទទួលបញ្ជាក់រាល់ លិខិតស្នាមគតិយុត្តិ ឬកិច្ចសន្យាទាំងឡាយ ដែលរូបវន្តបុគ្គល ឬនីតិបុគ្គលនៃនីតិឯកជន ឬនីតិបុគ្គលនៃនីតិសាធារណៈ មានកាតព្វកិច្ចតាមច្បាប់កំណត់ ឬឆន្ទៈរបស់ខ្លួនឯង
- បញ្ជាក់ធានាហត្ថលេខា និងកាលបរិច្ឆេទ នៃលិខិតស្នាមគតិយុត្ត ឬកិច្ចសន្យា
- ផ្តល់យថាភូតភាព លើឯកសារបកប្រែពីភាសាបរទេស មកភាសាខ្មែរ និងពីភាសាខ្មែរទៅភាសាបរទេស
- ធ្វើសំណើរចុះបញ្ជី និងលេខាចារឹកទៅស្ថាប័នមានសមត្ថកិច្ច
- ធ្វើការរក្សាទុកច្បាប់ដើម នៃលិខិតស្នាមគតិយុត្ត និងកិច្ចសន្យា
- ធ្វើការរក្សាទុកមរតកសាសន៍ ច្បាប់ដើម
- ចេញច្បាប់ចម្លង នៃលិខិតយថាភូត និង
- ទទួលធ្វើ និងបញ្ជាក់រាល់លិខិតស្នាមគតិយុត្ត ផ្សេងទៀតដែលអនុញ្ញាតដោយច្បាប់។

### ១.១.២.៤ ក្រោយក្រមរដ្ឋប្បវេណី ២០០៧ ចូលជាធរមាន

ក្រមរដ្ឋប្បវេណី ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ និងច្បាប់ស្តីពីការអនុវត្តន៍ក្រមរដ្ឋប្បវេណី ដែលប្រកាសឲ្យប្រើដោយព្រះ-រាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ បានលើកឡើងអំពីលិខិតយថាភូត និងតួនាទីរបស់សារការីក្នុងមុខងារជាអ្នកធ្វើលិខិតយថាភូត ព្រមទាំងមន្ត្រីទទួលបន្ទុកកិច្ច

ការសារការី ដែលត្រូវបានតែងតាំងដើម្បីបំពេញកិច្ចការ សារការីជាបណ្តោះអាសន្ន[6]។ ដើម្បីបំពេញកិច្ចការសារការីបន្ទាប់ពីអនុវត្តក្រមរដ្ឋប្បវេណីមក ក្រសួងយុត្តិធម៌បានចេញប្រកាសពីរ គឺប្រកាសលេខ ៤៧ កយ ប្រក/១២ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ និង ប្រកាសលេខ ៣២ កយ ប្រក/១២ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២ ស្តីពីការកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការី ហើយត្រូវបំពេញកិច្ចការនេះរហូតដល់មានច្បាប់ស្តីពីលក្ខន្តិកៈសារការី។

សរុបមក ទោះបីជាមុខងារនៃវិជ្ជាជីវៈសារការី មានការវិវត្តន៍ជាច្រើនចាប់តាំងពីមានព្រះរាជក្រម៩១០ន.ស ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ រហូតមកដល់បច្ចុប្បន្ន ក៏មុខងារនៃវិជ្ជាជីវៈសារការីពុំមានការផ្លាស់ប្តូរដដែល ពោលគឺមុខងារចំបងរបស់សារការី គឺជាមន្ត្រីសាធារណៈដែលបំពេញបេសកកម្ម និងមុខងារសាធារណៈដើម្បីផលប្រយោជន៍របស់រដ្ឋ ទោះបីជាមានលក្ខន្តិកៈជាវិជ្ជជីវៈសេរីក៏ដោយ មុខងារក្នុងការធ្វើលិខិតយថាភូត ផ្តល់យថាភូតភាពចំពោះលិខិត និងកិច្ចសន្យាទាំងឡាយដែលច្បាប់បានប្រគល់ឲ្យ។

មុខងាររបស់សារការី ដូចដែលបានរៀបរាប់ខាងលើ គឺជាអ្នកធ្វើលិខិតយថាភូត។ តើអ្វីទៅជាលិខិតយថាភូត?

**លិខិតយថាភូត** នៅក្នុងសន្ទានុក្រមនៃក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩៦៧ និងច្បាប់ភូមិបាលឆ្នាំ១៩៩២ ព្រមទាំងច្បាប់ភូមិបាល ឆ្នាំ២០០១ បានផ្តល់និយមន័យដូចៗគ្នាថា ៖

" **លិខិតយថាភូត** គឺជាលិខិតដែលធ្វើតាមរូបមន្តច្បាប់ ដូចជាលិខិតបញ្ជាក់ជាដើម "។

យោងតាមនិយមន័យនេះ នាំឲ្យលេចឡើងនូវចំណោទបញ្ហាសំខាន់ៗ មួយចំនួនដូចខាងក្រោម៖

តើយើងអាចយល់ច្បាស់ ឬនៅ អំពីនិយមន័យនៃលិខិតយថាភូត?

សន្ទានុក្រមនៃក្រមរដ្ឋប្បវេណីចាស់ ព្រមទាំងច្បាប់ភូមិបាលឆ្នាំ១៩៩២ ក៏ដូចជាច្បាប់ភូមិបាលឆ្នាំ២០០១ មិនបានធ្វើការកំណត់ឲ្យបានដាច់ណាត់អំពីអត្ថន័យច្បាស់លាស់នៃ លិខិត-យថាភូតនោះទេ។សន្ទានុក្រមទាំងនេះគ្រាន់តែបានផ្តល់អត្ថន័យថា លិខិតយថាភូតជាលិខិត ដែលធ្វើតាមរូបមន្តនៃច្បាប់ ដូចជា **លិខិតបញ្ជាក់** ជាដើម។

តើអ្វីទៅជាលិខិតបញ្ជាក់?

[6] មាត្រា ៩ និងមាត្រា ១០ នៃច្បាប់ស្តីពីការអនុវត្តន៍ក្រមរដ្ឋប្បវេណី ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១។

យោងតាមមាត្រា៩៤៤ នៃក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩៦៧ បានបញ្ញត្តិថា៖

" **លិខិតបញ្ជាក់** គឺសំបុត្រដែលគូភាគីបានចុះហត្ថលេខា ក្រោយដែលគេបានអានសេចក្ដីសំបុត្រទាំងអស់យ៉ាងខ្លាំងៗ ដោយក្បោះក្បាយអោយភាគីស្ដាប់ចំពោះមុខ មន្ត្រីនៃរាជការសាធារណៈ។ មន្ត្រីនេះក្រោយដែលបានពិនិត្យ អំពីអត្តសញ្ញាណ ការចូលមកនៃគូភាគី និងការអានលិខិតឲ្យគូភាគីស្ដាប់ អំពីហត្ថលេខាដែលភាគីបានចុះនោះឃើញថាត្រឹមត្រូវហើយ ទើបចុះហត្ថលេខាខ្លួនឯងក្បែរហត្ថលេខានៃគូភាគីព្រមទាំងបោះត្រាផង[៩]"។

ឆ្លងតាមរយៈការបង្ហាញខាងលើ យើងអាចយល់បានថា លិខិតយថាភូតពុំត្រូវបាន ផ្ដល់អត្ថន័យដោយមាត្រាច្បាប់ណាមួយនោះទេ។ សញ្ញាណនៃលិខិតយថាភូតនេះ គឺមានតែនៅក្នុងសទ្ធានុក្រមដែលភ្ជាប់ទៅនឹងច្បាប់ ដូចបានអធិប្បាយខាងលើប៉ុណ្ណោះ។ ផ្ទុយទៅវិញ និយមន័យនៃ លិខិតយថាភូត ដែលបានពន្យល់នៅក្នុងសទ្ធានុក្រមទាំងនោះ មានទំនាក់ទំនងគ្នាយ៉ាងខ្លាំងទៅនឹងអត្ថន័យ នៃលិខិតបញ្ជាក់ ហើយដែលលិខិតបញ្ជាក់នេះគឺមានចែងយ៉ាងច្បាស់ទាំងខ្លឹមសារ ទាំងបែបបទនៃការអនុវត្ត ព្រមទាំងមន្ត្រីដែលមានសមត្ថកិច្ចអនុវត្តផងដែរ។

តើលិខិតបញ្ជាក់ និងលិខិតយថាភូតមានទំនាក់ទំនងគ្នាយ៉ាងដូចម្ដេច?

អនុលោមតាមមាត្រា ៩៤៥ នៃក្រមរដ្ឋប្បវេណីចាស់បានចែងថា ៖

"...ប៉ុន្តែ លិខិតទាំងឡាយគ្រប់ប្រភេទដែលមានដាក់តម្លៃត្រឹម ឬលើសពី ២០០.០០០ រៀលឡើងទៅ ត្រូវតែឲ្យសារការីបញ្ជាក់តាមទម្រង់នៃអាជីវកម្មរបស់គេ[១០]"។

ម្យ៉ាងទៀតមាត្រា ៩៦១ នៃក្រមរដ្ឋប្បវេណីចាស់ដដែលនេះ បានចែងថា៖

" (ព្រះរាជក្រម៩១០ ន.ស ៤-១១-៥៤) ក្រៅអំពីលិខិតដែលបានបង្ហាញហើយនៅក្នុងមាត្រា៩៤៤ និងតទៅនោះ លិខិតទាំងឡាយដូចខាងក្រោមត្រូវចាត់ទុកជាលិខិតបញ្ជាក់ដែរ៖

១/ លិខិតទាំងពួងដែលកុងស៊ុល ឬទូតខ្មែរធ្វើនៅបរទេស តាមរូបមន្តយថាភូតនៃសារការីខ្មែរ ក្នុងព្រំដែននៃអំណាចដែលរាជការខ្មែរ សម្រេចឲ្យធ្វើបានក្នុងរឿងនេះ។

[៩] តាមរយៈសទ្ធានុក្រមនៃក្រមរដ្ឋប្បវេណីចាស់បានឲ្យនិយមន័យលិខិតបញ្ជាក់ថា ជាលិខិតដែលមេឃុំ ឬ ចាហ្វាយស្រុកបានសូត្រខ្លាំងៗ ច្បាស់ៗ ឲ្យគូភាគីស្ដាប់ ហើយចុះហត្ថលេខា ខ្លួនជាមួយនិងគូភាគី លើលិខិតនោះ។

[១០] មានចែងផងដែរនៅមាត្រា ៣ នៃព្រះរាជក្រមលេខ ៩១០ នស ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ១៩៥៤ ដែលចែងថា ប៉ុន្តែតទៅមុខទៀត មានតែសារការីទេ ដែលអាចបញ្ជាក់តាមទម្រង់ការមុខក្រសួងខ្លួននូវលិខិតគ្រប់ប្រភេទ បើកាលណាលិខិតនោះមានចុះទឹកប្រាក់ចំនួនស្មើនិងលើសពី ២០០ ០០០រៀល។

២/ លិខិតទាំងពួង ដែលមន្ត្រីសាធារណៈបានធ្វើតាមរូបមន្តយថាភូត។ មន្ត្រីសាធារណៈគឺសារការី ក្រឡាបញ្ជី ដែលរាជការបារាំងបានតែងតាំងឲ្យធ្វើជាសារការីផង ឬដែលរាជការបារាំងបានអនុញ្ញាត ឲ្យធ្វើជាបណ្តោះអាសន្នក្រោយពី ការផ្ទេរសមត្ថកិច្ចជូនមករាជរដ្ឋាភិបាលខ្មែរ ពេញផ្ទៃប្រទេស ទម្រាម់មានសេចក្តីសម្រេចអំពីរឿងនេះជាថ្មី។

៣/ លិខិតយថាភូតទាំងឡាយ ដែលអាជ្ញាធរបរទេសជាអ្នកមានសមត្ថកិច្ច បានធ្វើនៅឯបរទេស តាមរូបមន្តដែលច្បាប់ខ្មែរបានបញ្ញត្តិទុកមក។

៤/ លិខិតយថាភូត ទាំងពួងធ្វើនៅប្រទេសខ្មែរដោយកុងស៊ុល ឬ ទូតបរទេសដែលទទួលការតែងតាំងជាត្រឹមត្រូវឲ្យនៅអមព្រះរាជរដ្ឋាភិបាលខ្មែរ កាលណាបើកុងស៊ុល ឬទូតនោះប្រព្រឹត្តក្នុងមុខងារជាសារការី ក្នុងព្រំដែនដែលច្បាប់អន្តរជាតិសាធារណៈទទួលស្គាល់ ឬដែលអនុសញ្ញាទូត ឬកុងស៊ុលនោះទៅនឹងព្រះរាជរដ្ឋាភិបាលខ្មែរ”។[...]

យោងតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីចាស់ និងព្រះរាជក្រម ៩១០ ន.ស ឆ្នាំ១៩៥៤ ដូចដែលបានលើកឡើងខាងលើនេះ យើងអាចសន្និដ្ឋានអំពីទំនាក់ទំនងនៃលិខិតបញ្ជាក់ និងលិខិតយថាភូតបានដូចខាងក្រោម៖

- ទី១. លិខិតយថាភូតដែលធ្វើឡើងដោយសារការី ជាប្រភេទមួយនៃលិខិតបញ្ជាក់[១១] ។
- ទី២. លិខិតទាំងឡាយ ដែលមានដាក់តម្លៃចាប់ពី ២០០.០០០រៀល ឡើងទៅត្រូវបញ្ជាក់ដោយសារការី។ ត្រង់នេះអាចអោយយើងសន្និដ្ឋានបានថា លិខិតទាំងឡាយដែលបំពេញលក្ខខណ្ឌបែបនេះគឺជា លិខិតយថាភូត។ រីឯលិខិត ដែលមានដាក់តម្លៃក្រោម ២០០.០០០រៀល ជាលិខិតបញ្ជាក់ដែលត្រូវបញ្ជាក់ ដោយអាជ្ញាធរមូលដ្ឋាន( ចៅហ្វាយស្រុក ឬមេឃុំ)។

ប៉ុន្តែ បើផ្អែកលើធរមានបញ្ញត្តិបច្ចុប្បន្ន យើងមិនអាចធ្វើការបែងចែកភាពខុសគ្នារវាងលិខិតបញ្ជាក់ និងលិខិតយថាភូតឡើយ ដោយសារតែពុំមានបញ្ញត្តិណាមួយចែងឲ្យបានច្បាស់លាស់អំពីភាពខុសគ្នានេះឡើយ។

ម្យ៉ាងវិញទៀត បើយើងពិនិត្យមើលសញ្ញាណនៃលិខិតយថាភូតនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ-២០០៧ដែលនៅជាធរមាន និងកំពុងអនុវត្តនៅពេលបច្ចុប្បន្ននេះ ក៏ពុំឃើញមានបទប្បញ្ញត្តិនៃមាត្រាណាមួយផ្តល់និយមន័យដល់លិខិតយថាភូតនោះទេ។

[១១] មាត្រា ៩៦១ នៃក្រមរដ្ឋប្បវេណីចាស់

ក៏ដូចជាច្បាប់មុនៗដែរ លិខិតយថាភូតត្រូវនាបានកំណត់អត្ថន័យ នៅក្នុងសន្ទានុក្រមផ្នែករដ្ឋប្បវេណីនៃក្រមនេះដោយបានកំណត់ខ្លឹមសារថាៈ

" **លិខិតយថាភូត** ជាលិខិតធ្វើតាមរូបមន្តច្បាប់ដោយមន្ត្រីសាធារណៈ ដែលត្រូវបានអនុញ្ញាតឲ្យប្រត្តិបត្តិមុខងារនោះ។ តាមន័យចង្អៀត លិខិតយថាភូត គឺជាលិខិតទាំងឡាយដែលរៀបចំឡើងដោយសារការី"។

ប្រហាក់ប្រហែលនឹងអត្ថន័យ ដែលផ្តល់ឲ្យដោយសទ្ទានុក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ខាងលើ សន្ទានុក្រមបារាំង-ខ្មែរ នៃពាក្យច្បាប់របស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានឲ្យនិយមន័យនៃលិខិតយថាភូតថាៈ

" **លិខិតយថាភូត** ជាលិខិតលាយលក្ខណ៍អក្សរដែលធ្វើឡើងដោយមន្ត្រីសាធារណៈ ដូចជាសារការីជាដើម។ សេចក្តីអះអាងរបស់មន្ត្រីនេះ ក្នុងលិខិតនេះមានតម្លៃខ្ពស់បំផុត ដែលគេត្រូវជឿទុកចិត្តថាត្រឹមត្រូវលើកលែងតែមានការប្តឹងចោទប្រកាន់ជាមុនថាជាលិខិតក្លែង។ លិខិតយថាអាចអនុវត្តដោយបង្ខំបាន[១២]"។

សទ្ទានុក្រមនៃក្រមរដ្ឋប្បវេណីថ្មី និងសទ្ទានុក្រមបារាំង-ខ្មែរខាងលើ ហាក់ផ្តល់និយមន័យមានលក្ខណៈក្បោះក្បាយជាងសទ្ទានុក្រមនៃក្រមរដ្ឋប្បវេណីចាស់ និងធរមានប្បញ្ញត្តិនានាដែលបានអត្ថធិប្បាយខាងដើម ដោយវាបានផ្តល់លក្ខណៈពិស្តារនៅក្នុងន័យចង្អៀតមួយថា "**លិខិតយថាភូត ជាលិខិតទាំងឡាយណាដែលរៀបចំឡើងដោយសារការី**"។

តាមរយៈការលើកឡើងខាងលើ យើងឃើញថា ទោះបីជាមានការផ្តល់អត្ថន័យនៃ"លិខិតយថាភូត" ដោយឈរលើមូលដ្ឋាន នៃការវិវត្តប្រព័ន្ធច្បាប់តាំងពីក្រមរដ្ឋប្បវេណីចាស់ ព្រះរាជក្រមលេខ ៩១០ ឆ្នាំ១៩៥៤ ច្បាប់ភូមិបាលឆ្នាំ១៩៩២ ច្បាប់ភូមិបាលឆ្នាំ២០០១ ព្រមទាំងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ យ៉ាងណាក៏ដោយ ក៏ការកំណត់អត្ថន័យលិខិតយថាភូតហាក់ដូចជាពុំទាន់មានឯកសណ្ឋានភាពមួយពិតប្រាកដ និងពុំមានវិសាលភាពច្បាស់លាស់នៅឡើយ។ ទន្ទឹមនឹងនេះដែរ ពាក្យ "លិខិតយថាភូត" នៅក្នុងសទ្ទានុក្រមនៃក្រមរដ្ឋប្បវេណីថ្មីឆ្នាំ២០០៧ ក៏បានលើកឡើងស្រ-ដៀងគ្នា នឹងសទ្ទានុក្រមនៃក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩៦៧ ច្បាប់ភូមិបាលឆ្នាំ១៩៩២ ក៏ដូចជាច្បាប់ភូមិបាលឆ្នាំ២០០១ ផងដែរ ត្រង់ចំណុចដែលថា " **លិខិតយថាភូតជាលិខិតធ្វើឡើងតាមរូបមន្តនៃច្បាប់**"។

[១២] មាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី

## ១.២ លក្ខខណ្ឌដើម្បីបានទទួលមុខងារជាសារការី

បើយើងក្រឡេកមើលចាប់តាំងពីការកកើតសារការីមក ពោលគឺចាប់តាំងពីរមុនមានក្រមរដ្ឋប្បវេណីចាស់មករហូតមកដល់បច្ចុប្បន្ន គេពុំទាន់ឃើញមានបញ្ញត្តិណាចែងជាក់លាក់អំពីលក្ខខណ្ឌដើម្បីទទួលបានពីរមុខងារសារការីនោះទេ ក្រៅពីរាជក្រមលេ ៩១០ ន.ស ចុះថ្ងៃទី០៤ វិច្ឆិកា ឆ្នាំ១៩៥៤ ។

មាត្រា៧ នៃរាជក្រមលេខ ៩១០ ន.ស ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ បេក្ខជនដែលសមកាន់តំណែងជាសារការីត្រូវមាន សញ្ជាតិខ្មែរ មានសិទ្ធិជាពលរដ្ឋ និងនយោបាយ ហើយត្រូវមានអាយុចាប់ពី ៣០ឆ្នាំយ៉ាងតិច មានសញ្ញាបត្រច្បាប់ ឬថ្នាក់បណ្ឌិតច្បាប់ មានបទពិសោធន៍ការងារ យ៉ាតិចពីរឆ្នាំនៅក្នុងមន្ទីសារការី ដែលតាំងនៅប្រទេសខ្មែរ ឬប្រទេសណាមួយក្នុងសហភាពបារាំង។

ចំពោះបេក្ខជនដែលមានសមត្ថភាពច្បាប់ ឬមានសញ្ញាបត្រសមមូល និងសមត្ថភាពច្បាប់ព្រមទាំងបេក្ខជនដែលមានសញ្ញាបត្រវិជ្ជាស្ថានយុត្តិធម្មសាស្ត្រ និងសេដ្ឋសាស្ត្ររបស់ជាតិ [១៣] រយៈពេលនៃបទពិសោធន៍ត្រូវមានយ៉ាងតិច៥ឆ្នាំ (មាត្រា៨ ស្តីពីអន្តរបញ្ញត្តិ)។

ទី១. ក្នុងរយៈពេល៣ឆ្នាំ ចាប់ពីថ្ងៃដែលព្រះរាជក្រមនេះចូលជាធរមាន រាជរដ្ឋាភិបាលអាចតែងតាំឲ្យកាន់តំណែងជាសារការី ដោយមិនគិតនៅបទពិសោធន៍នៅបេក្ខជនណា ដែលបានបំពេញលក្ខខណ្ឌ អាយុ សញ្ជាតិ និង សីលធម៌ពេញបរិបូណ៌ តាមមាត្រា៧ ខាងលើនេះ ហើយឲ្យបេក្ខជននោះត្រូវមានសញ្ញាបត្រផង។

ទី២. បេក្ខជនណាដែលមានត្រឹមសញ្ញាបត្រ សមត្ថភាពច្បាប់ ឬមានសញ្ញាបត្រសមមូល និងសមត្ថភាពច្បាប់ អាចតែងតាំងក្នុងតំណែងសារការីក្នុងកំណត់ពេល ៥ឆ្នាំ ហើយបេក្ខជននោះទុកជាបានបំពេញលក្ខណៈ អាយុ សញ្ជាតិ និងសីសធម៌ពេញបរិបូណ៌តាមធម្មតា។ លុះផុតរយៈពេល៥ឆ្នាំហើយ បេក្ខជននេះទុកជាបានបំពេញសមត្ថកិច្ច មានបទពិសោធន៍ដោយហាត់ធ្វើការហើយត្រូវតែងតាំងបេក្ខជននោះអស់មួយជីវិត។

ទី៣. បេក្ខជនណាដែលគ្មានសញ្ញាបត្រ តែត្រូវបានបញ្ជាក់ថាបានធ្វើការប្រកបវិជ្ជាជីវៈចំនួន ១៥ឆ្នាំ ក្នុងក្របខណ្ឌជាន់ខ្ពស់ ក្នុងរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា អាចត្រូវតែងតាំងជាសារការីក្នុងរយៈពេល៥ឆ្នាំ។ លុះចប់រយៈពេល៥ឆ្នាំហើយ អាចធ្វើការតែងតាំងជាថ្មីបាន ប្រសិនបើបេក្ខជននោះបានបំពេញ លក្ខខណ្ឌ អាយុ សញ្ជាតិ និងសីសធម៌ពេញបរិបូណ៌។ បេក្ខជនជំពូកនេះ អាច

[១៣] វិជ្ជាស្ថានយុត្តិធម្មសាស្ត្រ និងសេដ្ឋសាស្ត្ររបស់ជាតិ (INEJE) គឺបង្កើតឡើងមុនមហាវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ក្រោយមកបានលុបចោល ជំនួសដោយមហាវិទ្យាល័យក្រោយនេះវិញនាឆ្នាំ១៩៥៩។

តែងតាំងអស់មួយជីវិតបាន បើប្រសិនបើជាខ្លួនមានសញ្ញាបត្រសមត្ថភាពច្បាប់ ឬសញ្ញាបត្រសមមូល និងសមត្ថភាពច្បាប់រយៈពេល ៥ឆ្នាំ ដែលបានតែងតាំងខ្លួនជាបណ្ដោះអាសន្ន។ ការតែងតាំងអស់មួយជីវិត មិនអាចធ្វើបានទេបើសាមីខ្លួន មិនទាន់ធ្វើជាមេមន្ទីសារការី រយៈពេល៥ឆ្នាំនោះ។

តាមមាត្រា៩ ការតែងតាំងសារការីត្រូវធ្វើតាមព្រះរាជក្រឹត្យ តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ព្រះរាជក្រឹត្យនេះ ត្រូវកម្រិតប្រាក់ធានា ដែលមេមន្ទីត្រូវបង់មុន និងទទួលសម្បថសច្ចាប្រណិធានផង។ តាមព្រះរាជក្រមលេខ ៩១០ ប្រាក់ធានាត្រូវបានកម្រិតដូខាងក្រោមនេះៈ

១/ ដាក់ប្រាក់ធានា ៥០០.០០០រៀល ក្នុងគណនីឃ្លាំងធនាគារ ឬគ្រឹះស្ថានចងការប្រាក់ ដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានអនុញ្ញាត

២/ បញ្ជាក់ថា ខ្លួនមានអសង្ហារឹមនៅប្រទេសខ្មែរ ផុតចាកពីការដាក់ធានាបញ្ចាំ និងការបញ្ចាំទាំងអស់ អាចបញ្ចាំជាតម្លៃតាមក្បួនប្រថាប់ត្រាបានយ៉ាងតិច ១.០០០.០០០រៀល មុននឹងទទួលសម្បថសច្ចាប្រណិធាន សាមីខ្លួនត្រូវដាក់បញ្ចាំអសង្ហារឹមនេះ ជាប្រយោជន៍ឃ្លាំងប្រាក់ជាតម្លៃ ១.០០០.០០០រៀល។

ទាំងនេះគឺជាលក្ខខណ្ឌ ដែលតម្រូវឲ្យបេក្ខជនបំពេញដើម្បីក្លាយខ្លួនជាសារការី បើយោងតាមព្រះរាជក្រមខាងលើ។

ប៉ុន្តែ ដោយព្រះរាជក្រមនេះ មិនត្រូវបានគេយកមកអនុវត្ត រហូតមកដល់បច្ចុប្បន្ននេះទេ បើទោះបី ជាគ្មានបញ្ញត្តិណានិរាករណ៍ព្រះរាជក្រមនេះក៏ដោយ ទើបមានសំនួរចោទឡើងថា តើនៅពេលបច្ចុប្បន្ននេះ យើងត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះដើម្បីទទួលបាននូវមុខងារជាសារការី?

### ១.២.១ ការទទួលបានមុខងារសារការីដោយអនុក្រឹត្យ

ដោយមានតម្រូវការជាចាំបាច់នូវមុខងារសារការី ក្នុងការប្រត្តិបត្តិការនានាលើវិស័យអចលនវត្ថុ និងក៏ដូចជាវិស័យដែលពាក់ព័ន្ធដែលតម្រូវឲ្យមាន ការចុះបញ្ជី ដើម្បីឲ្យការផ្ទេរកម្មសិទ្ធិ នោះមានសុពលភាព ហើយដោយសព្វថ្ងៃនេះ ពុំទាន់មានសារការីគ្រប់គ្រាន់នៅក្នុងប្រត្តិបត្តិការនោះផង រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យ៥០៥ អនក្រ/តតចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១ តែងតាំង លោក **ប៉ែន សុនសម័យ** ដែលជាសមាជិកមេធាវី នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នូវមុខងារបន្ថែមជា **មេធាវីសារការី** ។ មាត្រា២ មេធាវីសារការីជាមន្ត្រីសាធារណៈ ទទួលបាននូវអំណាចតាមការតែងតាំងនៃអនុក្រឹត្យនេះ។ ហើយដែលត្រូវបានកំណត់ ដោយរាជរដ្ឋាភិបាលជាមន្ត្រីសាធារណៈទទួលមុខងារសាធារណៈ ឲ្យប្រកបវិជ្ជាជីវៈសេរីជាសារការីហើយតម្រូវឲ្យមានទីតាំងត្រឹមត្រូវ ដើម្បីធ្វើជាមន្ទីសារការីមានទ្រព្យធន និងមូលនិធិគ្រប់គ្រាន់សម្រាប់ធានាបំណុលរដ្ឋ និងការខូចខាតដល់

អតិថិជន។ មួយវិញទៀត តម្រូវឲ្យតម្កល់ប្រាក់ធានាសំណងមួយចំនួនធំ នៅធានាគារជាតិនៃកម្ពុជា ដែលចែងក្នុងបញ្ញត្តិនៃមាត្រា៤ នៃអនុក្រឹត្យនេះ " **មេធាវីសារការី** ត្រូវតំកល់ប្រាក់ធានាចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលានរៀល) នៅធានាគារជាតិនៃកម្ពុជា សម្រាប់ទទួលខុសត្រូវក្នុងមុខការនេះ។

នេះគឺជាការទទួលបានមុខងារជាមេធាវីសារការី ដោយការតែងតាំងដោយអនុក្រឹត្យនេះទៅឲ្យសមាជិកមេធាវីនៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាដើម្បីបំពេញមុខងារជាសារការី ដើម្បីបំពេញសេចក្តីត្រូវការនៅមុខងារសារការីនេះនៅក្នុងសង្គម។

ទោះបីជាមានការតែងតាំងខាងលើនេះហើយក៏ដោយ ក៏សារការីនៅតែមានចំនួនមួយតិចនៅឡើយ បើប្រៀបធៀបទៅនឹងសេចក្តីត្រូវការរបស់សង្គមនៅមុខងារនេះ។ ដោយមើលឃើញនូវកង្វះខាតនៃសារការី ដើម្បីបំពេញមុខងារនេះនៅក្នុងជីវភាពប្រចាំថ្ងៃនោះ រដ្ឋាភិបាលក៏បានចេញអនុក្រឹត្យមួយទៀតលេខ ១៩៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៨ ទទួលស្គាល់**មន្ទីសារ-ការី អេច ប៊ី អេស** នៃព្រះរាជាណាចក្រកម្ពុជា។ ដោយអនុក្រឹត្យនេះ បានតែងតាំងសារការី ចំនួនពីររូបទៀត។ មន្ទីសារការីនេះ មានទីតាំងស្ថិតនៅអគារពាណិជ្ជកម្ម សូម៉ា ផ្លូវលេខ ១២០ សង្កាត់ផ្សារថ្មីទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ[១៤]។ ហើយមន្ទីសារការីនេះត្រូវដឹកនាំដោយ សារការី **លី តៃសេង** ជាប្រធាន និងសារការី **តាន់ ហ៊ាង ដាវ័ណ្ណ**[១៥]។

អនុក្រឹត្យនេះក៏តម្រូវផងដែរ នូវការដាក់ប្រាក់តម្កល់ចំនួន ៦០០.០០០.០០០លានរៀល នៅរតនាគារជាតិនៃកម្ពុជា សម្រាប់ធានាការទទួលខុសត្រូវក្នុងការបំពេញភារកិច្ចរបស់ខ្លួន[១៦]។

នេះគឺជាការទទួលបានមុខងារជា សារការីដោយអនុក្រឹត្យតែងតាំង ពីសំណាក់រាជរដ្ឋាភិបាល ដើម្បីទទួលបានមុខងារ ក៏ដូចជាបង្កើតមន្ទីសារការីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ១.២.២ ការតែងតាំងដោយប្រកាសនៅមន្ត្រីទទួលបន្ទុកកិច្ចការសារការី

ដោយមានការចាំបាច់និងកង្វះសារការីដើម្បីបំពេញមុខងារ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានចេញប្រកាសលេខ ៤៧ កយ.ប្រក/១២ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១០១២ ដើម្បីតែងតាំងមន្ត្រីជាច្រើនទៀត ដើម្បីទទួលបន្ទុកអនុវត្តជាបណ្តោះអាសន្ន នូវកិច្ចការសារការីរហូតដល់មានសារការី

[១៤] មាត្រា២ នៃអនុក្រឹត្យលេខ ១៩៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ២០០៨
[១៥] មាត្រា៤ នៃអនុក្រឹត្យលេខ ១៩៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ២០០៨
[១៦] មាត្រា៥ នៃអនុក្រឹត្យលេខ ១៩៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ២០០៨

ដែលមានវិជ្ជាជីវៈចេញមកពីការបណ្តុះបណ្តាល ឬមានបទប្បញ្ញត្តិផ្ទុយពីប្រកាសនេះទើបមន្ត្រីទទួលបន្ទុកនោះត្រូវចប់ភារកិច្ចរបស់ខ្លួន។ ហើយឈ្មោះមន្ត្រីទទួលបន្ទុកសារការី ដែលកំណត់ដោយប្រកាសនេះបានត្រូវកំណត់ក្នុងប្រការ១[១៧] នៃប្រកាសនេះ ៖

ប្រការ១ ត្រូវបានកំណត់ជាមន្ត្រីទទួលបន្ទុកកិច្ចការសារការី នៅតាមដែនសមត្ថកិច្ច នៃសាលាដំបូងសាមីខ្លួន ៖

ក. រាជធានីភ្នំពេញ

១ .ឯកឧត្តម ផូវ សំភី

២.ឯកឧត្តម ហ្វូត ហាក់

ខ. ខេត្តកណ្តាល

១.ឯកឧត្តម កើត រិទ្ធ

២.ឯកឧត្តម វង្ស ប៊ុនវិសុទ្ធ

គ.ខេត្តកំពុងចាម

១.លោក ផាន់សុភក្រ្តិ

២.លោក សម ប៊ុនថុន

ឃ. ខេត្តព្រៃវែង

១. លោក កើតវណ្ណារ៉េត

២. លោក គី ម៉ានេវ៉ា

ង.ខេត្តសៀមរាប

១. លោក អ៊ិត សុធា

២. លោក ស្រ៊ា រតនៈ

ច. ខេត្តបន្ទាយមានជ័យ

១. លោក ផាន់ វណ្ណារ័ត្ន

២. លោក ផាន់ ភីរម្យ

ឆ. ខេត្តបាត់ដំបង

១. លោក សាអឿន កោសល្យមុន្នី

[១៧] ប្រការ១ នៃប្រកាសរបស់ក្រសួងយុត្តិធម៌លេខ៤៧ កយ.ប្រក/១២ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២

២. លោក ហ៊ីង ប៊ុនថន

ជ. ខេត្តពោធិ៍សាត់

១. លោក កុល កំពូល

២. លោក ប៉ង់ ចាន់សុយុទ្ធារា

មន្ត្រីទទួលបន្ទុកកិច្ចការសារការី ដែលបានរាយនាមខាងលើនេះ ត្រូវអនុវត្តកិច្ចការសារការី នៅក្នុងដែនសមត្ថកិច្ចនៃសាលាដំបូងរបស់ខ្លួន ស្ថិតនៅក្នុងកំឡុងពេលរហូតដល់កាលបរិច្ឆេទនៃការអនុវត្តច្បាប់ស្តីពីលក្ខន្តិកៈនៃសារការី ឬ បទប្បញ្ញត្តិផ្សេងដែលចែងនិរាករណ៍ប្រកាសនេះ។

មន្ត្រីទទួលបន្ទុកកិច្ចការសារការី[១៨] ត្រូវធ្វើការរបស់សារការីដែលមានកំណត់ ក្នុងក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី និងធ្វើការចាត់ចែងផ្សេងទៀតដែលកំណត់ក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌។

ក្រោយពីបានអនុវត្តមួយរយៈរួចមក ប្រកាសលេខ៤៧ កយ.ប្រក/១២ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ក៏បានត្រូវនិរាករណ៍ ដោយប្រកាសរបស់ក្រសួងយុត្តិធម៌លេខ ៣២ កយ.ប្រក/១២ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២ ដែលបានចែងថា "ប្រកាសលេខ ៤៧ កយ.ប្រក/ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់ក្រសួងយុត្តិធម៌ត្រូវទុកជានិរាករណ៍[១៩]។ ហើយដែលបានតែងតាំងមន្ត្រីទទួលបន្ទុកសារការីបន្ថែមច្រើនជាងមុននៅក្នុងប្រកាសនេះដែលមានចែងក្នុងប្រការ១"[២០] ៖

ប្រការ១ ៖ ត្រូវបានកំណត់ជាមន្ត្រីទទួលបន្ទុកសារការី នៅតាមដែសមត្ថកិច្ចនៃសាលាដំបូងសាមីខ្លួនដែលមានរាយនាមដូចខាងក្រោម ៖

ក.រាជធានីភ្នំពេញ

១. ឯកឧត្តម ហួត ហាក់

២. ឯកឧត្តម ផូវ សំភី

ខ.ខេត្តកណ្តាល

១.ឯកឧត្តម កើត រិទ្ធ

២.លោក វង្ស ប៊ុនវិសុទ្ធ

[១៨] ប្រការ២ នៃប្រកាសរបស់ក្រសួងយុត្តិធម៌លេខ៤៧ កយ.ប្រក/១២ ចុះថ្ងៃទី ១៦កុម្ភៈ ឆ្នាំ២០១២

[១៩] ប្រការ៣ នៃប្រកាសរបស់ក្រសួងយុត្តិធម៌លេខ៣២ កយ.ប្រក/១២ ចុះថ្ងៃទី ២៣ ខែឧសភាឆ្នាំ២០១២

[២០] ប្រការ១ នៃប្រកាសរបស់ក្រសួងយុត្តិធម៌លេខ៣២ កយ.ប្រក/១២ ចុះថ្ងៃទី ២៣ ខែឧសភាឆ្នាំ២០១២

គ.ខេត្តកំពង់ឆ្នាំង

១.ឯកឧត្តម ហ៊ែល ចំរើន

២.លោក កុល កំពូល

ឃ.ខេត្តកំពង់ស្ពឺ

១.ឯកឧត្តម ស៊ូ សុជាតិ

២.លោក ងួន ណារ៉ា

ង.ខេត្តកំពត

១.ឯកឧត្តម កាន ច័ន្ទមេត្តា

២.លោក អ៊ីវ ត្រាយ

ច.ខេត្តព្រះសីហនុ

១.ឯកឧត្តម ឡាំ ជា

២.លោក វៀម ច័ន្ទម្នី

ឆ.ខេត្តកោះកុង

១.លោក គុប ឈុនហេង

២.លោក ហុង សុគុណវឌ្ឍនា

ជ.ខេត្តតាកែវ

១. លោក មាស សុភក្តិ

២.ឯកឧត្តម អ៊ុំង សេរីវិសុទ្ធ

ឈ.ខេត្តស្វាយរៀង

១.ឯកឧត្តម គឹម សន្តិភាព

២.លោក យក់ ប៊ុនណា

ញ.ខេត្តព្រៃវែង

១.លោក សាយ ណូរ៉ា

២.លោក សម ប៊ុនថុន

ត.ខេត្តកំពុងចាម

១.លោក ផាន់ សុភ័ក្ត្រ

២.លោក ប៊ុន យ៉ៃណារិន

ថ.កំពង់ធំ

១. លោក អ៊ិត សុធា

២. លោក សារឿន កោសល្យមុនី

ទ.ខេត្តក្រចេះ

១.លោកស្រី ចាត សូរស្មី

២.ឯកឧត្តម សំ រិទ្ធី

ធ.ខេត្តពោធិ៍សាត់

១.លោក ប៉ង់ ចាន់សុយុទ្ធារា

២.លោក សៀង ធីរិទ្ធ

ន.ខេត្តបាត់ដំបង

១.លោក ហ៊ីងប៊ុថន

២.លោក ផាន់ ភីរម្យ

ដ.ខេត្តប៉ៃលិន

១.លោក ជុំ សែនសទ្ធា

២.លោក អ៊ី សារិញ

ប.ខេត្តបន្ទាយមានជ័យ

១.លោក ផាន់ វណ្ណរ័ត្ន

២. លោក គី ម៉ានេវ៉ា

ឱ.ខេត្តសៀមរាប

១.លោក កើត វណ្ណារ៉េត

២.លោក ស្រ៊ា រតនៈ

ឈ.ខេត្តឧត្តរមានជ័យ

១.លោក កូយ កាន់យ៉ា

២.ឯកឧត្តម បួន សុមុនី

ណ.ខេត្តព្រះវិហារ

១.លោក ជុំ ស

២.ឯកឧត្តម កៅ ថាច

ប.ខេត្តរតនៈគិរី

១.លោក លាវ ស្រេង

មន្ត្រីទទួលបន្ទុកសារការីទាំងអស់នេះត្រូវបានតែងតាំងឲ្យ អនុវត្តកិច្ចការសារការីក្នុងអំឡុងពេលរហូតដល់កាលបរិច្ឆេទ នៃការអនុវត្តច្បាប់ស្តីពីលក្ខន្តិកៈនៃសារការី។

មន្ត្រីទទួលបន្ទុកកិច្ចការសារការី ត្រូវធ្វើកិច្ចការរបស់សារការី ដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី និងធ្វើការចាត់ចែងផ្សេងទៀតដែលមានកំណត់ក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌[២៣]។

មូលហេតុដែលបង្កើតប្រកាសមួយនេះឡើង ដើម្បីនិរាករណ៍ប្រកាសលេខ ៤៧ កយ.ប្រក/១២ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ព្រោះដោយសារតម្រូវការជាចាំបាច់នៅមុខងារសារការីបន្ថែមក្នុងការបំពេញមុខងារនេះនៅក្នុងពេលបច្ចុប្បន្ន។

### ១.២.៣ សារការីកំពុងបណ្តុះបណ្តាល

សាលាភូមិន្ទសារការីនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវបានបង្កើតឡើងតាមអនុក្រឹត្យលេខ ១១៧ អនក្រ បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨ ដែលមានបេសកកម្មធ្វើការបណ្តុះបណ្តាលបន្តសម្រាប់សារការី។

សិស្សសារការី របស់សាលាភូមិន្ទសារការីនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវឆ្លងកាត់ការបណ្តុះបណ្តាលរយៈពេល៣០ខែ បន្ទាប់ពីបានប្រលងជាប់នៅវិញ្ញាសារ ដែលបានដាក់ជូនដើម្បីមានសិទ្ធិទទួលការបណ្តុះបណ្តាលនេះ។ ការបណ្តុះបណ្តាលនេះចែកចេញជាពីរដំណាក់កាល៖

- ដំណាក់កាលធ្វើសិក្ខាគារិកមានរយៈពេល១២ខែ
- ដំណាក់កាលធ្វើកម្មសិក្សា មានរយៈពេល១៨ ខែ

ដើម្បីទទួលបាននៅការបណ្តុះបណ្តាលនៅសាលាសារការីបាន គេត្រូវឆ្លងកាត់ការបំពេញបែបបទ និង លក្ខខណ្ឌនៃការប្រលងប្រជែងជ្រើសរើសសិស្សសារការីជាមុនសិន។

- ❖ បែបបទ និង លក្ខខណ្ឌនៃការប្រលងប្រជែងសិស្សសារការីមានដូចខាងក្រោម៖
- បេក្ខជនទាំងពីរភេទត្រូវមានសញ្ជាតិខ្មែរ។ ចំពោះបេក្ខជនជានិស្សិត ត្រូវមានអាយុមិនលើសពី ៣៥ឆ្នាំ រីឯបេក្ខជនជាមន្ត្រីរាជការត្រូវមានអាយុមិនលើសពី ៤០ឆ្នាំ គិតមកត្រឹមថ្ងៃប្រលង
- ត្រូវមានបរិញ្ញាបត្រនីតិសាស្ត្រឡើងទៅ

[២៣] ប្រការ២ នៃប្រកាសរបស់ក្រសួងយុត្តិធម៌លេខ៣២ កយ.ប្រក/១២ ចុះថ្ងៃទី ២៣ ខែឧសភាឆ្នាំ២០១២

- ត្រូវមានលិខិតថ្កោលទោសបញ្ជាក់ថា មិនធ្លាប់មានទោសពីបទមជ្ឈឹម ឬបទឧក្រិដ្ឋ និង
- ត្រូវមានកាយសម្បទាគ្រប់គ្រាន់

❖ ការប្រលងប្រជែងជ្រើសរើសសិស្សសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវបានចែកចេញជាពីរដំណាក់កាលគឺ ៖

**១.ដំណាក់កាលទី១ ៖ វិញ្ញាសារសរសេរ (វិញ្ញាសារបង្ខំ)** ដែលមានមុខវិជ្ជា នីតិកាតព្វកិច្ច និងកិច្ចសន្យា នីតិអចលនទ្រព្យ នីតិជំនួញ និង ភាសាបារាំង។

**២.ដំណាក់កាលទីពីរ៖ វិញ្ញាសារ សួរផ្ទាល់មាត់(វិញ្ញាសារជ្រើសរើស)** ដែលមានមុខវិជ្ជា នីតិគ្រួសារ នីតិពាណិជ្ជកម្ម នីតិអចលនទ្រព្យ និង នីតិរដ្ឋបាល។ បេក្ខជនត្រូវជ្រើសរើសមួយក្នុងចំណោមមុខវិជ្ជាទាំងអស់ខាងលើ សម្រាប់ឆ្លើយនិងសំនួររបស់គណៈមេប្រយោគ។ ប្រសិនបើយល់ឃើញថាមានការចាំបាច់ នោះគណៈមេប្រយោគអាចសួរសំណួរបន្ថែម ទៅបេក្ខជនលើមុខវិជ្ជាបីផ្សេងទៀតដែលនៅសល់។

ទាំងអស់នេះ គឺជាវិញ្ញាសាប្រឡងដើម្បីបានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈសារការី នៅសាលាភូមិន្ទសារការី។

បន្ទាប់ពីបានទទួលបានលទ្ធផលប្រឡងជាប់ហើយនោះ សិស្សសារការីនិងត្រូវបានទទួលការតែងតាំងដោយប្រកាសរបស់ទីស្តីការគណៈរដ្ឋមន្ត្រីជាសិស្សសារការី[២២]។ ជាក់ស្តែងក្នុងពេលថ្មីៗនេះ សិស្សសារការីជំនាន់ទី១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវបានទីស្តីការគណៈរដ្ឋមន្ត្រីតែងតាំងដោយប្រកាសលេខ ១៧ ប្រក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ ដែលមានចំនួន១៥នាក់។

### ១.២.៣.១ កម្មវិធីបណ្តុះបណ្តាលសារការី

- រយៈពេលបណ្តុះបណ្តាល២ឆ្នាំ និង៦ខែ
- ដំណាក់កាលបណ្តុះបណ្តាល៖
    - បណ្តុះបណ្តាលបឋម ( ១ឆ្នាំស្មើនឹង៤ត្រីមាស)
    - កម្មសិក្សា និងការជួបជុំប្តូរបទពិសោធន៍នានា(១៨ឆ្នាំ)
- ចំនួនម៉ោងសរុប = ១០៨០ (១ត្រីមាស = ២៧០ ម៉ោង)

[២២] ប្រការ១នៃប្រកាស លេខ១៧ ប្រកចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការតែងតាំងសិស្សសារការី ជំនាន់ទី១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

**ក បណ្តុះបណ្តាលបឋម ៖**

**ក.១ ត្រីមាសសិក្សាអំពីនីតិទូទៅ**

| | |
|---|---|
| ១. នីតិកាតព្វកិច្ច និងកិច្ចសន្យាពិសេស | ៦០ម៉ោង |
| ២. ស្ថាប័នតុលាការ និងស្ថាប័នរដ្ឋបាល | ៤០ម៉ោង |
| ៣.សញ្ញាណនានាស្តីពីបច្ចេកទេសអនុវត្តក្នុងវិជ្ជាជីវៈសារការី (លិខិតសារការីក្រមសីលធម៌ការទទួលខុសត្រូវរបស់សារការី) | ៥៥ម៉ោង |
| ៤. នីតិវិធីអនុវត្តសេចក្តីសម្រេច | ៥០ម៉ោង |
| ៥. ភាសាបារាំង | ១៥ម៉ោង |
| ៦. សិក្ខាសិលា | |

**ក.២ ត្រីមាសសិក្សាអំពីនីតិគ្រួសារ**

| | |
|---|---|
| ១. នីតិបាតិបុគ្គលនិងអសមត្ថជន | ៤០ម៉ោង |
| ២. នីតិរបបមាតិកភ័ណ្ឌ | ៥០ម៉ោង |
| ៣.នីតិសន្តតិកម្ម និងសទ្ធាទាន | ៦០ម៉ោង |
| ៤. នីតិគ្រួសារ (សិក្សាពីទិដ្ឋភាពជម្រះបញ្ជីមាតិកភ័ណ្ឌនិងមរតក) | ៧០ម៉ោង |
| ៥. ភាសាបារាំង | |

**ក.៣ ត្រីមាសសិក្សាអំពីនីតិអចលនៈទ្រព្យ**

| | |
|---|---|
| ១. នីតិអចលនៈទ្រព្យ និងកម្មសិទ្ធិលើអចលនៈទ្រព្យ | ៧០ម៉ោង |
| ២. នីតិឥណទានអចលនៈវត្ថុ | ៤០ម៉ោង |
| ៣.នីតិប្រាតិភោគ | ៦០ម៉ោង |
| ៤. នីតិសាងសង់ និងនគរូបណីយកម្ម | ៥០ម៉ោង |
| ៥. ភាសាបារាំង | ៥០ម៉ោង |

**ក.៤ ត្រីមាសសិក្សាអំពីនីតិជំនួញ**

| | |
|---|---|
| ១. នីតិពាណិជ្ជកម្ម(មូលនិធិពាណិជ្ជកម្ម និងប្រតិបត្តិការដែលពាក់ព័ន្ធ ភតិសន្យាពាណិជ្ជកម្ម) | ៦០ម៉ោង |
| ២. នីតិក្រុមហ៊ុន | ៥៥ម៉ោង |
| ៣.នីតិព្រហ្មទណ្ឌនៃជំនួញ | ៤០ម៉ោង |
| ៤. ទម្រង់បែបបទ និងពន្ធដារសារការី (អចលនៈវត្ថុពាណិជ្ជកម្មគ្រួសារ) | ៥០ម៉ោង |
| ៥. ភាសាបារាំង | ៥០ម៉ោង |
| ៦. សិក្ខាសាលា | ១៥ម៉ោង |

### ១.២.៣.២ កម្មសិក្សានិងការជួបជុំផ្លាស់ប្តូរបទពិសោធន៍

#### ក. កម្មសិក្សានិងការបណ្តុះបណ្តាលឆ្លាស់

- កម្មសិក្សារយៈពេល៦ខែ នៅតាមបណ្តាមន្ទីរសារការីនៅប្រទេសបារាំង
- ការបណ្តុះបណ្តាលឆ្លាស់រយៈពេល ៩ខែ នៅប្រទេសកម្ពុជា (រៀន១ថ្ងៃនៅសាលាភូមិន្ទសារការី និងចុះកម្មសិក្សា៤ខែ)៖
  - កម្មសិក្សាចំនួន ៨៦៤ម៉ោង នៅតាមបណ្តាលស្ថាប័ននានា(រដ្ឋបាលសុរិយោដី រដ្ឋបាលពន្ធដារ អាជ្ញាធរដែនដីជាដើម)
  - **ការបណ្តុះបណ្តាលឆ្លាស់៖**

| | |
|---|---|
| - ច្បាប់ភូមិបាល( រដ្ឋបាសសូរិយោដីជាដើម) | ៩៦ម៉ោង |
| - នីតិសាងសង់និងនគរូបនីយកម្ម ( ឯកសារនគរូបនីយកម្មលិខិតអនុញ្ញាតសាងសង់ជាដើម) | ៤០ម៉ោង |
| - នីតិសារពើពន្ធ (សារពើពន្ធអចលនវត្ថុពន្ធប្រថាប់ត្រាចុះបញ្ជីជាដើម) | ៤០ម៉ោង |
| - ឯកសាររដ្ឋបាល (សំបុត្រកំណើតជាដើម) | ៤០ម៉ោង |
| - ភាសាបារាំង | ៥០ម៉ោង |

#### ខ. ការជួបជុំផ្លាស់ប្តូរបទពិសោធន៍

- នៅពេលចាប់ផ្តើមវគ្គបណ្តុះបណ្តាលការណែនាំឲ្យស្វែងយល់ពីច្បាប់ថ្មីៗ

- នៅពេលត្រឡប់ពីកម្មសិក្សានៅប្រទេសបារាំង៖ វិភាគសិក្សាអំពីការអនុវត្តជាក់ស្តែងខាងផ្នែកសារការីដោយភ្ជាប់ទៅ នឹងការបរិច្ឆេទក្នុងស្រុក។

នេះគឺជាការបណ្តុះបណ្តាល ដើម្បីទទួលបានមុខងារ ក៏ដូចជាតួនាទីជាសារការីតាមរយៈការប្រឡងចូលសាលាភូមិន្ទវិជ្ជាជីវៈសារការី។

ដោយសារតែយើងពុំទាន់មានបទប្បញ្ញត្តិជាក់លាក់ ដើម្បីកំណត់អំពីការទទួលបានមុខងារជាសារការី ដូច្នេះហើយបានជាយើងឃើញថា ការទទួលបាននៅមុខងារជាសារការីមានលក្ខណៈមិនច្បាស់លាស់ដូច្នេះ។ ហើយបើយើងក្រឡេកមើល សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈសារការីឆ្នាំ២០០៧ គេបានកំណត់យ៉ាងច្បាស់លាស់នៅមាត្រា៥ គឺដើម្បីទទួលបានមុខងារសារការី ឬចូលប្រកបវិជ្ជាជីវៈសារការីបានលុះត្រាតែ៖

- មានសញ្ជាតិខ្មែរ

- មានបរិញ្ញាបត្រច្បាប់
- បានបំពេញយ៉ាងពេញលេញរាល់ការទាមទារនូវ ការបណ្តុះបណ្តាល កម្មសិក្សា និងសញ្ញា-បត្រដែលកំណត់នៅក្នុងច្បាប់នេះ។
- មិនដែលជាកម្មវត្ថុនៃការផ្តន្ទាទោស ថ្នាក់មជ្ឈឹម ឬឧក្រិដ្ឋ និងមិនដែលត្រូវប្រកាសក្ស័យធនផ្ទាល់ខ្លួនដោយសេចក្តីសម្រេចរបស់តុលាការ។

ចំណែកមាត្រា៦ "សារការីត្រូវបានតែងតាំង ដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ក្រោយពីបានបញ្ចប់ការបណ្តុះបណ្តាលនៅសាលាភូមិន្ទសារការី និងកម្មសិក្សាដោយបង្ខំ បើសិនជាសារការីទាំងអស់នោះបានបំពេញយ៉ាងពេញលេញនូវរាល់ លក្ខខណ្ឌនៃការប្រលងចេញ របស់សាលាភូមិន្ទសារការី។ សារការីអាចប្រកបមុខងាររបស់ខ្លួន ចាប់តាំងពីថ្ងៃដែលបានតែងតាំង ដោយប្រកាសរបស់ក្រសួងយុត្តិធម៌។

នេះគឺជាលក្ខខណ្ឌដែលបានចែង នៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈសារការី ឆ្នាំ២០០៧ ដែលបានចែងអំពីការទទួលបាននៅមុខងារជាសារការី។ ប៉ុន្តែដោយហេតុថា វានៅតែជាសេចក្តីព្រាងច្បាប់នៅឡើយ យើងក៏ពុំអាចយកវាជាសំអាង ក្នុងការបកស្រាយអំពីលក្ខខណ្ឌដើម្បីទទួលបានមុខងារជាសារការីនៅពេលបច្ចុប្បន្ននោះដែរ។

តាមរយៈការរៀបរាប់ខាងលើនេះ យើងឃើញថាដើម្បីទទួលនបានតួនាទី ក៏ដូចជាមុខងារជាសារការី គឺលុះត្រាតែបុគ្គលនោះបានទទួលការតែងតាំងអនុក្រឹត្យ ប្រកាស និង តាមរយៈការបណ្តុះបណ្តាលចេញពីសាលាភូមិន្ទវិជ្ជាជីវៈសារការី។

នៅពេលដែលបានទទួលមុខងារ និង តួនាទីជាសារការីរួចហើយតើសារការីអនុវត្តមុខងារ និងតួនាទីទាំងនោះទៅលើកិច្ចសន្យាអ្វីខ្លះ? យើងនិងសូមលើកយកមកបកស្រាយនៅការអនុវត្តមុខងាររបស់សារការី ( **ជំពូកទី២ ការអនុវត្តមុខងារ និងតួនាទីរបស់សារការី**) ដូចខាងក្រោម។

# ជំពូកទី២ ការអនុវត្តមុខងារ និងតួនាទីរបស់សារការី

នៅក្នុងជំពូកទី២ យើងនិងលើកយកការអនុវត្តមុខងារ របស់សារការីមកបកស្រាយ បន្ទាប់ពីការទទួលបាននៅមុខងារជាសារការីដែលបានបកស្រាយនៅក្នុងជំពូកទី១ ខាងលើនេះ។ ហើយនៅក្នុងជំពូកទី២នេះយើងនិងបែងចែកជាពីរផ្នែកគឺ **២.១ មុខងារ និងតួនាទីរបស់សារការី** និង **២.២ បញ្ហាប្រឈមក្នុងការអនុវត្តន៍មុខងាររបស់សារការី**។

## ២.១ មុខងារ និង តួនាទីរបស់សារការី

### ២.១.១ មុខងារដែលមានបញ្ញត្តិក្នុងច្បាប់

យោងតាមប្រការ ២ នៃប្រកាសលេខ ៤៧ កយ.ប្រក/១២ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់ក្រសួងយុត្តិធម៌ បានកំណត់តួនាទីរបស់មន្ត្រីទទួលបន្ទុក កិច្ចការសារការីថា ត្រូវធ្វើកិច្ចការរបស់សារការីដែលមានកំណត់ក្នុង ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី និងការចាត់ចែងផ្សេងៗទៀត ដែលកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ មន្ត្រីទទួលបន្ទុកកិច្ចការសារការីនេះ អនុវត្តកិច្ចការរបស់សារការី រហូតដល់ច្បាប់ស្តីពីលក្ខន្តិកៈសារការីត្រូវបានអនុវត្ត។

តួនាទីរបស់សារការី និងមន្ត្រីទទួលបន្ទុកកិច្ចការសារការីមានជាអាទិ៍៖

- ធ្វើលិខិតយថាភូតសម្រាប់ការធ្វើអនុប្បទាន នូវកម្មសិទ្ធិលើអចលនវត្ថុ ឬសម្រាប់ធ្វើលទ្ធកម្មសិទ្ធិលើអចលនវត្ថុ[៣៣]
- ធ្វើលិខិតយថាភូតសម្រាប់ការបង្កើតហ៊ីប៉ូតែក និង ការចាត់ចែងហ៊ីប៉ូតែក ដូចជា ការធ្វើហ៊ីប៉ូតែកបន្ត ការធ្វើអនុប្បទានហ៊ីប៉ូតែក ការបោះបង់ហ៊ីប៉ូតែក ការធ្វើអនុប្បទានលំដាប់ហ៊ីប៉ូតែក ការបោះបង់លំដាប់ហ៊ីប៉ូតែក និងការប្តូរលំដាប់ហ៊ីប៉ូតែក[៣៤]
- ធ្វើមតកសាសន៍តាមទម្រង់លិខិតយថាភូត ដើម្បីឲ្យមតកសាសន៍នោះមានអានុភាពតាមផ្លូវច្បាប់[៣៥]

[៣៣] ក្រមរដ្ឋប្បវេណី ២០០៧ មាត្រា ៣៣៦

[៣៤] ក្រមរដ្ឋប្បវេណី ២០០៧ មាត្រា ៨៦២, ៨៥៩, ៨៦០,៨៦១,៨៩៥

[៣៥] ក្រមរដ្ឋប្បវេណី ២០០៧ មាត្រា១១៧៣

- កិច្ចសន្យាត្រូវបង្កើតឡើង ដោយការព្រមព្រៀងរវាងភាគី ទាំងសងខាងតែប៉ុណ្ណោះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់។ ប៉ុន្តែ ភាគីអាចកំណត់ការធ្វើលិខិតយថាភូត ឬ លិខិតឯកជនជាលក្ខខណ្ឌសម្រាប់ការបង្កើតកិច្ចសន្យាបាន[២៦]
- ទទួលធ្វើសេចក្តីបញ្ជាក់ ចំពោះលក្ខន្តិកៈរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ដើម្បីឲ្យលក្ខន្តិកៈនោះមានអានុភាព[២៧]
- ទទួលធ្វើសេចក្តីបញ្ជាក់ ចំពោះការកែប្រែលក្ខន្តិកៈរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ដើម្បីឲ្យលក្ខន្តិកៈនោះមានអានុភាព[២៨]
- ទទួលធ្វើសេចក្តីបញ្ជាក់ ចំពោះលក្ខន្តិកៈរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ដើម្បីឲ្យលក្ខន្តិកៈនោះមានអានុភាព[២៩]
- ទទួលធ្វើសេចក្តីបញ្ជាក់ ចំពោះការកែប្រែលក្ខន្តិកៈរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ដើម្បីឲ្យលក្ខន្តិកៈនោះមានអានុភាព[៣០]
- ទទួលធ្វើសេចក្តីបញ្ជាក់ ចំពោះលក្ខន្តិកៈរបស់នីតិបុគ្គលមូលធន ដើម្បីឲ្យលក្ខន្តិកៈនោះមានអានុភាព[៣១]
- ធ្វើការចុះនិទ្ទេស និងចុះហត្ថលេខាលើលិខិតឯកជនដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវតាមច្បាប់ ឬបញ្ជាក់ពីកាលបរិច្ឆេទស្ថាពរនៃលិខិតឯកជននោះ[៣២]
- ដើម្បីធ្វើលិខិតយថាភូត មន្ត្រីទទួលបន្ទុកកិច្ចការសារការីមានករណីកិច្ចត្រួតពិនិត្យ និងបញ្ជាក់អត្តសញ្ញាណ របស់ភាគីដោយសាក្សី ឬសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត[៣៣]។

[២៦] ក្រមរដ្ឋប្បវេណី ២០០៧ មាត្រា៥១៦
[២៧] ក្រមរដ្ឋប្បវេណី ២០០៧ មាត្រា៨២
[២៨] ក្រមរដ្ឋប្បវេណី ២០០៧ មាត្រា៩៧
[២៩] ក្រមរដ្ឋប្បវេណី ២០០៧ មាត្រា១០១
[៣០] ក្រមរដ្ឋប្បវេណី ២០០៧ មាត្រា១០៩
[៣១] ក្រមរដ្ឋប្បវេណី ២០០៧ មាត្រា១១០
[៣២] ច្បាប់ស្តីពីការអនុក្រមរដ្ឋប្បវេណី ២០០៧ មាត្រា៨,៩

ចំណែកឯនៅក្នុង ច្បាប់ភូមិបាលឆ្នាំ២០០១ ក៏បានកំណត់បញ្ញត្តិក្នុងមាត្រាមួយចំនួនដូចខាងក្រោមនេះដែរ ៖

- ការផ្ទេរកម្មសិទ្ធិមិនអាចជំទាស់ពីតតិយជនបាន លុះត្រាតែកិច្ចសន្យាលក់ អចលនវត្ថុនោះត្រូវបានធ្វើជាលាយលក្ខណ៍អក្សរតាម ទម្រង់យថាភូតដោយអាជ្ញាធរមានសមត្ថកិច្ចហើយត្រូវបានចុះបញ្ជីនៅក្រសួងសុរិយោដី។ កិច្ចសន្យាលក់តែឯកឯង មិនអាចចាត់ទុកជាការផ្ទេរកម្មសិទ្ធិទ្រព្យនោះពេញលក្ខណៈច្បាប់បានឡើយ[៣៤]។
- អ្នកលក់ ត្រូវធានាជាមួយអ្នកទិញក្នុងកិច្ចសន្យាចំពោះអចលនវត្ថុ ដែលលក់នៅរាល់វិការៈអាចិកំបាំងសំខាន់ៗ បើពុំនោះទេនាំឲ្យមានកតិកាភេទនៃការលក់[៣៥]។
- លទ្ធកម្មដោយការដូរអចលនវត្ថុ ត្រូវមានលក្ខណ្ឌដូចការលក់អចលនវត្ថុដែរ[៣៦]។
- ប្រទានកម្មអចលនវត្ថុ មិនអាចត្រូវបានជំទាស់ពីតតិយជនបាន លុះត្រាតែប្រទានកម្មនោះត្រូវបានធ្វើជាលាយលក្ខណ៍អក្សរតាមទម្រង់យថាភូត ហើយត្រូវបានចុះបញ្ជីនៅអង្គភាពសុរិយោដី[៣៧]។
- កិច្ចសន្យាផលុភោគ និងយកជាការបានលុះត្រាតែ បានធ្វើលិខិតតាមរូបមន្តយថាភូត[៣៨]។
- សិទ្ធិប្រើប្រាស់ និងអាស្រ័យផលនៅកើតឡើងនិងបាត់បង់ទៅវិញ តាមបែបនៃផលុភោគដែរ។ សិទ្ធិនៃអ្នកប្រើប្រាស់ និងអាស្រ័យនៅ កំណត់ដោយខចែងក្នុងកិច្ចសន្យាតាមរូបមន្តលិខិតយថាភូត ឬដោយបញ្ញត្តិនៃច្បាប់ដែលចែងអំពីសិទ្ធិនេះ[៣៩]។
- កិច្ចសន្យាដាក់ធានា ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ តាមរូបមន្តយថាភូត និងចុះលេខាចារឹកក្នុងបញ្ជីសុរិយោដី[៤០]។

[៣៣] ច្បាប់ស្តីពីការអនុក្រមរដ្ឋប្បវេណី ២០០៧ មាត្រា១១
[៣៤] មាត្រា ៦៥ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១
[៣៥] មាត្រា ៦៨ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១
[៣៦] មាត្រា ៧០ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១
[៣៧] មាត្រា ៨១ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១
[៣៨] មាត្រា ១២០ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១
[៣៩] មាត្រា ១៣៩ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១
[៤០] មាត្រា ២២០ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១

- ➢ កិច្ចសន្យាហ៊ីប៉ូតែក ត្រូវរៀបចំតាមរូបមន្តយថាភូតចំពោះអាជ្ញាធរមានសមត្ថកិច្ច ឬអ្នកច្បាប់ណាម្នាក់ដែលមាននីតិសម្បទាក្នុងរឿងនេះ។ អាជ្ញាធរមានសមត្ថកិច្ចក្នុងការតាក់តែងកិច្ចសន្យាហ៊ីប៉ូតែក និងទម្រង់នៃការចុះបញ្ជី និងកំណត់ដោយអនុក្រឹត្យ[៤១]
- ➢ កិច្ចសន្យាបញ្ចាំអចលនវត្ថុ ត្រូវធ្វើជាលាយលក្ខណ៍អក្សរតាមរូបមន្តយថាភូត ដោយអាជ្ញាធរមានសមត្ថកិច្ច ហើយត្រូវចុះបញ្ជីនៅក្រសួងសុរិយោដី[៤២]។

សរុបមកយើងឃើញថា សារការីគឺជាមន្ត្រីសាធារណៈដែលមានសមត្ថកិច្ចក្នុងការអនុវត្ត និងទទួលធ្វើលិខិតយថាភូត ទាំងអស់ខាងលើនេះដែលធរមានបញ្ញត្តិបានប្រគល់ឲ្យ ដើម្បីឲ្យលិខិតទាំងអស់នេះមានសុពលភាពយកទៅអនុវត្ត។ តើសារការីអនុវត្តនៅបទប្បញ្ញត្តិខាងលើនេះ តាមទម្រង់លិខិតរបស់ខ្លួន( **២.១.២ លិខិតរបស់សារការី** ) ក្នុងលក្ខណៈដូចម្តេច?

### ២.១.២ លិខិតរបស់សារការី

**លិខិតយថាភូត** ជាលិខិតរបស់សារការីសម្រេចតាមការព្រមព្រៀងរបស់គូភាគីតាំងពីដំបូង។ ក្នុងចំណោមលិខិតដែលមានអានុភាពនេះ គូភាគីសច្ចាប្រណិធានថានឹងអនុវត្តតាមខ្លឹមសារនៃការព្រមព្រៀងគ្នា។ សំខាន់ជាងនេះទៅទៀត លិខិតយថាភូតមានតម្លៃស្មើ នឹងសាលក្រមតុលាការ និងអាចអនុវត្តបាន[៤៣]។

ឧទាហរណ៍: អ្នកដែលឲ្យខ្ចីប្រាក់អាចសុំឲ្យព្រះរាជអាជ្ញាចេញលិខិតកាតព្វកិច្ច ដើម្បីអនុវត្តតាមលិខិតយថាភូត របស់សារការីដោយមិនតម្រូវឲ្យឆ្លងកាត់តាមនីតិវិធីតុលាការទេ។

លិខិតយថាភូតរបស់សារការី ក៏អាចយកទៅអនុវត្តបាននៅធនាគារ ឬស្ថានប័ណហិរញ្ញវត្ថុ ដើម្បីអនុវត្តទៅលើការលក់ឡាយឡុងចលនទ្រព្យ។នេះក៏ជាចំណុចសំខាន់មួយក្នុងដំណោះស្រាយយ៉ាងឆាប់រហ័សនៃវិវាទដែលកើតឡើងលើកិច្ចសន្យាដែរ។

បច្ចុប្បន្ននេះ តម្រូវការលទ្ធផលល្អភាពច្បាស់លាស់និងការមិនបង្អង់យូរនោះ គឺជាសារៈសំខាន់នៃលិខិតយថាភូត។ ដូចដែលបានអះអាង នៅក្នុងសុន្ទរកថារបស់រដ្ឋមន្ត្រីសេដ្ឋកិច្ចមួយនៃសហគមន៍អឺរ៉ុប បានលើកឡើងពីសារៈសំខាន់នៃលិខិតយថាភូតថា: "....គឺលិខិតយថាភូតនេះហើយដែលមានអានុភាពខ្លាំងខាងផ្លូវច្បាប់ ទៅលើភាគីដែលពាក់ព័ន្ធហើយ លិខិតយថាភូតនេះក៏ធ្វើឲ្យមាន

[៤១] មាត្រា ២០១ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១
[៤២] មាត្រា ២០៧ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១
[៤៣] មាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ភាពងាយស្រួលលើការអនុវត្តន៍ ពីព្រោះវាបានបញ្ជាក់ពីខ្លឹមសារច្បាស់លាស់ ដើម្បីជៀលវាងវិវាទដូចការសច្ចាប្រណិធាន នៅពាក្យចុងក្រោយនោះនឹងត្រូវបានឲ្យគេយកទៅអនុវត្តបាន"។

លិខិតយថាភូត នេះត្រូវបានគេទទួលស្គាល់ និងអនុវត្តបានជាអន្តរជាតិ។ ប្រព័ន្ធសេដ្ឋកិច្ចនៃប្រទេសនៅក្នុងសហគមន៍អឺរ៉ុបតាមអនុសញ្ញា Brussels នាថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៦៧ ត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ១៩៧៨ ដើម្បីឲ្យលិខិតយថាភូត អាចយកទៅអនុវត្តបានតាមច្បាប់ នៅប្រទេសដទៃ ក្រៅពីប្រទេសដែលធ្វើលិខិតយថាភូតនោះ។ ដូច្នេះ **លិខិតយថាភូត** មានអានុភាពអនុវត្តជាអន្តរជាតិផងដែរ។

សារការី ជាស្ថាប័នឯករាជ្យមួយ ដែលរាជរដ្ឋាភិបាលបានតែងតាំងឡើង ដែលមានតួនាទីយ៉ាងសកម្ម និងសំខាន់ក្នុងការតាក់តែងលិខិតគតិយុត្តិ ដោយសារការីបានផ្តល់ការពិគ្រោះយោបល់ និងបញ្ជាក់នូវបំណងពិតរបស់គូភាគីទាំងសងខាង ពីដើមដំបូងហើយនិងពន្យល់ហេតុផលទាំងនោះ។ ការផ្តល់យោបល់ធ្វើយ៉ាងណាឲ្យស្របតាមផ្លូវច្បាប់ទៀតផង។ **លិខិតយថាភូត** ត្រូវបានតម្កល់ទុកនៅ មន្ទីសារការីរហូតដល់ ១០០ឆ្នាំ។

តួនាទីសំខាន់មួយទៀតរបស់សារការីនោះ គឺការទទួលខុសត្រូវទាំងស្រុងលើខ្លឹមសារពិតដែលបានធ្វើឡើង។ សារការី ជាអាជ្ញាកណ្តាលដែលមិនលំអៀង ទៅលើភាគីណាមួយឡើយ ព្រមទាំងទទួលខុសត្រូវលើលិខិតគតិយុត្តទាំងឡាយ ដែលបានតាក់តែងឡើងតាមបំណងស្របច្បាប់របស់គូភាគី។

យថាភាពបានបើកផ្លូវយ៉ាងទូលំទូលាយ ដើម្បីធ្វើឲ្យសង្គមមានការអភិវឌ្ឍន៍រឹងមាំ និងសេរីដែលជាសេចក្តីត្រូវការរបស់សង្គម ហើយក៏ជាការសម្រួលរដ្ឋបាលជាក់លាក់នៃកិច្ចសន្យា និងការធ្វើឲ្យការអនុវត្តន៍ច្បាប់មានតំលៃខ្ពស់ទៅទៀតផង។

ប្រការដែលគួរឲ្យកត់សម្គាល់គឺថា: **លិខិតយថាភូត** ធ្វើឲ្យមានសុវត្ថិភាពតាមផ្លូវច្បាប់ ហើយទប់ស្កាត់មិនឲ្យចំណាយពេលវេលា និងថវិកាទៅលើវិវាទ។ តាមស្ថិតិរបស់ប្រទេសដែលអនុវត្តតាមសារការីប្រព័ន្ធច្បាប់ (Civil - Law) នោះគឺអត្រាវិវាទមានត្រឹមតែ០.០៥% ហើយបើប្រៀបធៀបទៅនឹងប្រទេសដែលអនុវត្តតាមសារការីប្រព័ន្ធច្បាប់ ( Common – law ) ដែលអត្រាវិវាទមានដល់ទៅ ៣០% ត្រូវដោះស្រាយនៅតុលាការ។

ជាការពិតណាស់ថា បច្ចុប្បន្នប្រព័ន្ធសារការីនេះមានប្រមាណ ១៦៦ប្រទេស ហើយ៦០% នៃប្រជាជនក្នុងពិភពលោក មានការយល់ដឹងនិងជឿជាក់លើ ប្រព័ន្ធសារការីច្បាប់រដ្ឋប្បវេណី ដើម្បីបម្រើផលប្រយោជន៍ស្របច្បាប់របស់ខ្លួនឲ្យបានប្រសើរឡើង។

សម្រាប់ប្រទេសកម្ពុជា ច្បាប់ជាធរមានពុំបានកំណត់ទម្រង់រូមណាមួយសម្រាប់លិខិតយថាភូត តាមទម្រង់សារការីឡើយ។ ប៉ុន្តែច្បាប់បានកំណតឲ្យលិខិតយថាភូត ត្រូវបំពេញនូវទម្រង់អតិបរមា សម្រាប់សកម្មភាពមួយចំនួន ដើម្បីឲ្យលិខិតនោះមានអានុភាព ដូចជា មតសាសន៍តាម ទម្រង់-យថាភូតជាដើម[៥៤]។ មតកសាសន៍ដោយលិខិតយថាភូត ដែលមានបញ្ញត្តិក្នុងមាត្រា១១៧៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ត្រូវបានចាត់ទុកថាជាលិខិតបង្កើតឡើងដោយសារការី តាមបញ្ញត្តិនៃមាត្រា៩ ចំនុច គ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីថ្មី។ មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើ-ឡើងដោយ យោងតាមទម្រង់ដែលមានចែងក្នុងមាត្រា១១៧៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ដែលមានជាអាទិ៍ វត្តមានរបស់សាក្សីយ៉ាងតិច២នាក់ ការសរសេរជាលាយលក្ខណ៍អក្សរ ដោយសារការីនូវអត្ថន័យរបស់មតកសាសន៍ ការសរសេរ ថ្ងៃ ខែ ឆ្នាំ ហើយចុះហត្ថលេខារបស់សារការីជាដើម។

ដោយសារលិខិតយថាភូត ត្រូវបង្កើតឡើងដោយមន្ត្រីសាធារណៈក្រោមទម្រង់ឱឡារិ[៥៥] ដែលមានលក្ខណៈ ដោយឡែកខុសពីលិខិតឯកជនបង្កើតឡើងតាមទម្រង់នៃការព្រមព្រៀងរបស់ គូភាគីឯកជនសុទ្ធសាធនោះ លិខិតត្រូវបំពេញលក្ខខណ្ឌទម្រង់មួយចំនួនដូចជា៖

### ២.១.២.១ វត្តមានរបស់គូភាគីហត្ថលេខី

វត្តមានរបស់គូភាគី គឺចាំបាច់ណាស់សម្រាប់ការតាក់តែងលិខិតយថាភូត ដែលអាចឲ្យនអ្នកបង្កើតលិខិតផ្ទៀងផ្ទាត់ច្បាស់លាស់អំពីអត្តសញ្ញាណ។ ចំពោះមតកសាសន៍ ដោយលិខិតយថាភូត ម្ចាស់បណ្តាំ ចាំបាច់ត្រូវមានវត្តមាននៅចំពោះមុខមន្ត្រីសារការីដើម្បីប្រាប់ផ្ទាល់មាត់ នៅខ្លឹមសារនៃមតកសាសន៍[៥៦]។ គូភាគីត្រូវមានវត្តមានក្នុងពេលចុះហត្ថលេខាលើលិខិត នៅចំពោះមុខសារការី។ ប៉ុន្តែប្រសិន បើម្ចាស់បណ្តាំមិនអាចសរសេរ និងចុះហត្ថលេខាបាននោះទេ សារការីអាចជំនួសការ

[៥៤] មាត្រា ១១៧០កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ២០០៧

[៥៥] យោងតាមវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ឧឡារិក(គុ) គ្រោត។ គ្រោតគ្រាត ច្បាស់លាស់។

[៥៦] មាត្រា ១១៧៣នៃក្រមរដ្ឋប្បវេណី ២០០៧

សរសេរ និងហត្ថលេខាដោយសរសេរ ឈ្មោះ អាយុ និង លំនៅឋានរបស់ជននោះ ហើយសរសេរបន្ថែមនៅហេតុផលនោះផង[៤៣]។

សារការីត្រូវផ្ទៀងផ្ទាត់អត្តសញ្ញាណ សមត្ថភាព និងអំណាចរបស់ជនដែលមានប្រយោជន៍។ យោងតាមបញ្ញត្តិនៃមាត្រា១១ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១[៤៤]។ មន្ត្រីទទួលបន្ទុកកិច្ចការសារការីត្រូវមាន ករណីកិច្ចប្រុងប្រយ័ត្ន ដោយយកចិត្តទុកដាក់ក្នុងការធ្វើលិខិតយថាភូត ដោយពិនិត្យនិងបញ្ជាក់អត្តសញ្ញាណរបស់គូភាគី ដោយសាក្សី ឬសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត និងតាមការកំណត់របស់ប្រកាសរបស់ក្រសួងយុត្តិធម៌។ ជាលទ្ធផល ការបញ្ជាក់ពីអត្តសញ្ញាណរបស់គូភាគី គឺជាបញ្ហាសំខាន់បំផុតដែលសារការីត្រូវយកចិត្តទុកដាក់ ក្នុងការធ្វើលិខិតយថាភូត ហើយករណីអវត្តមាននៃសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត សារការីគួរតែទាមទារ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារពាក់ព័ន្ធសំខាន់ៗផ្សេងទៀត។

លើសពីនេះទៅទៀត បើយោងតាមមាត្រា១៥ នៃព្រះរាជក្រម ៩១០ នស ចុះថ្ងៃទី០៤ ខែវិច្ឆិការ ឆ្នាំ១៩៥៤ មន្ត្រីសារការីត្រូវទទួលការ កាលណាបើមានគេមកសុំលើកលែង តែករណីដែលមានសម្តែងនូវមាត្រា១០ ឬកាលណាបើគូសញ្ញាទាំងអស់ ឬមួយណាជាជនវិកលលក្ខណៈ គ្មាននីតិសម្បទា បើកាលណាលិខិតមិនត្រឹមត្រូវតាមគន្លងច្បាប់ បើកាលណាគូសញ្ញាមិនបានបង់ប្រាក់ប្រថាប់ត្រា និងថ្លៃឈ្នួលបើមន្ត្រីនេះមិនស្គាល់គូសញ្ញា ហើយគូសញ្ញានេះមិនអាចបង្ហាញ អត្តសញ្ញាណរបស់ខ្លួន ដោយសំបុត្រស្នាម ឬដោយសាក្សី ២នាក់បាន ឬជាអវសាន្ត បើកាលណាសារការីមិនអាចនឹងទទួលបាន ដោយហេតុផលដៀលមិនរួច។ មានន័យថា សារការីមិនត្រឹមតែពិនិត្យលើអត្តសញ្ញាណរបស់គូភាគីប៉ុណ្ណោះទេ តែសារការីគឺថែមទាំងគប្បីពិនិត្យ ពីសមត្ថភាពរបស់គូភាគីផងដែរ នៅពេលបង្កើតកិច្ចសន្យានោះថែមទៀត។

### ២.១.២.២ វត្តមានរបស់សារការី

សារការី ត្រូវតែជាបុគ្គលមានសមត្ថភាព ដើម្បីបំភ្លឺគូភាគីលើលក្ខណៈសំខាន់ នៃកិច្ចសន្យារបស់គូភាគី ផលវិបាកនៃលិខិត និងផ្តល់ឲ្យគូភាគីនូវសេចក្តីពន្យល់ទាំងអស់ដែលចាំបាច់។សារការី

[៤៣] មាត្រា១១៧៣.យ នៃក្រមរដ្ឋប្បវេណី ២០០៧

[៤៤] ច្បាប់ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០១១ ហើយដែលត្រូវព្រឹទ្ធសភាបានអនុម័តយល់ព្រមទាំងស្រុងនៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ ២០១១ ព្រមទាំងព្រះមហាក្សត្រឡាយព្រះហស្តលេខាប្រកាសឲ្យប្រើនៅថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១១។

ត្រូវពិនិត្យមើលគុណភាព ដ៏ត្រឹមត្រូវនៃកិច្ចសន្យា និងធានាថាគូភាគីមានការព្រមព្រៀងដ៏ច្បាស់លាស់ពិតប្រាកដ និងមានសុពលភាពតាមផ្លូវច្បាប់[៤៩]។

យោងតាមបញ្ញត្តិនៃមាត្រា១ នៃព្រះរាជក្រម នស ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ សារការីមានករណីកិច្ច ត្រូវបំភ្លឺឲ្យដំណឹង និងទូន្មានគូសញ្ញាអំពីលិខិតដែលអ្នកនេះបានធ្វើ ឬមានបំណងនឹងធ្វើ ហើយត្រូវពិនិត្យឲ្យដឹងថា សេចក្តីកត់ចុះក្នុងលិខិតនោះត្រឹមត្រូវតាមការពិត។ ឧទាហរណ៍ តួនាទីសំខាន់របស់សារការីក្នុងលិខិតមតកសាសន៍ សារការីមិនត្រឹមតែសរសេរតាមអត្ថន័យ នៃមតកសាសន៍របស់ម្ចាស់បណ្តាំជាលាយលក្ខណ៍អក្សរប៉ុណ្ណោះទេ ថែមទាំងត្រូវសូត្រឲ្យម្ចាស់បណ្តាំ និងសាក្សីនោះស្តាប់[៥០]។

### ២.១.២.៣ វត្តមានសាក្សី

សាក្សី គឺតតិយជនដែលចូលរួមដឹងឮដល់កិច្ចគតិយុត្តណាមួយ ឬ ចូលរួមអះអាងបញ្ជាក់ទទួលស្គាល់កិច្ចគតិយុត្តណាមួយ។ ជាគោលការណ៍សាក្សីត្រូវតែជាសមត្ថជន[៥១]។ នៅក្នុងលិខិតយថាភូត ដែលបង្កើតឡើងដោយសារការី សាក្សីត្រូវតែមានវត្តមាននៅចំពោះមុខសារការី ដើម្បីបញ្ជាក់ពីភាពរឹងមាំនៃលិខិតនេះ។ តួយ៉ាងផ្អែកតាមបញ្ញត្តិនៃមាត្រា១១៧៣ ចំណុច ក នៃក្រមរដ្ឋប្បវេណី២០០៧ បានកំណត់ទម្រង់យថាភូតនៃមតកសាសន៍ ដោយតម្រូវឲ្យមានវត្តមានរបស់សាក្សីយ៉ាងតិចពីររូបនៅចំពោះមុខសារការី។

### ២.១.២.៤ ការចុះហត្ថលេខារបស់សារការី

ដោយខ្លួនជាមន្ត្រីសាធារណៈ សារការីត្រូវបានប្រគល់អំណាចជូនដោយច្បាប់ តាមរយៈប្រតិភូកម្មហត្ថលេខា ដើម្បីបញ្ជាក់នូវយថាភាពដល់លិខិតដែលទទួលធ្វើ និងសន្យាទទួលខុសត្រូវចំពោះភាពត្រឹមត្រូវតាមច្បាប់ និងកាលបរិច្ឆេទនៃលិខិតដែលខ្លួនបានធ្វើ ឬបញ្ជាក់។ មាត្រា៩ កថាខណ្ឌ ក នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ ចែងពីលិខិតដែលធ្វើឡើងដោយសារការី

[៤៩] សៀវភៅ ស្តីពីសន្និសិទពីមុខងារសារការីតាមបែបប្រទេសបារាំង ថ្ងៃទី១៧-១៨ ខែកុម្ភៈ ឆ្នាំ២០០៤ ទំព័រទី១៤

[៥០] មាត្រា ១១៧៣ ចំណុច គ នៃក្រមរដ្ឋប្បវេណី ២០០៧

[៥១] យោងតាមមាត្រា ១១៧២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ បញ្ញាតិថា បុគ្គលដែលមិនអាចធ្វើជាសាក្សីនៅពេលធ្វើមតកសាសន៍មានដូចជា អនីតិជន ឬជនដែលស្ថិតនៅក្រោយរបបអាណាព្យាបាលទូទៅ។ ជនដែលត្រូវបានសន្មត់ថាជាសន្តតិជន អច្ច័យលាភី ហើយនិងសហព័ទ្ធ និងញាតិលោហិតខ្សែផ្ទាល់របស់ជនទាំងនោះ ។ បើសារការីជានាក់ពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ជាលិខិតយថាភូត ឬជាលិខិតមតកសាសន៍សម្ងាត់ សហព័ន្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រលាបញ្ជី និងនិយោជិតរបស់សារការីនោះ។

ឬលិខិតឯកជនដែលសារការីចុះនិទ្ទេសថាលិខិតនោះ មានភាពត្រឹមត្រូវតាមច្បាប់ និងចុះកាលបរិច្ឆេទ និងហត្ថលេខាក្រោយពេលខ្លួនបញ្ជាក់ថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់។

សារការី មុននិងចុះហត្ថលេខាលើលិខិតត្រូវតែធ្វើការស្រាវជ្រាវលើ លិខិតរដ្ឋបាលផ្សេងៗដែលពាក់ព័ន្ធជាច្រើនទៀត ដើម្បីជៀសវៀងការទទួលខុសត្រូវនាពេលអនាគត ដោយសារការធ្វេសប្រហែលរបស់ខ្លួន។ នៅថ្ងៃចុះហត្ថលេខាលើលិខិត សារការីត្រូវធ្វើការប្រជុំគូរភាគី ដើម្បីធ្វើការអានលិខិត ដើម្បីបញ្ជាក់ពីវត្តមានរបស់គូភាគី ហើយក៏ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃអត្ថន័យនៃលិខិតដែលការធ្វើបែបនេះវានិងមិនអាចត្រូវបាន ជំទាស់ដោយគូភាគីលើខ្លឹមសារនៃលិខិតនាពេលអនាគត។

### ២.១.២.៥ ការប្រថាប់ត្រារបស់សារការី

ព្រះរាជក្រមលេខ ៩១០ នស ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤ ក៏ដូចជាបញ្ញត្តិនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ ព្រមទាំងអនុក្រឹត្យលេខ ១៤៤ ស្តីពីការទទួលស្គាល់ មន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៨ ពុំបានបញ្ញត្តិអំពីការប្រថាប់ត្រា បន្ទាប់ពីសារការីចុះហត្ថលេខាឡើយ។ ប៉ុន្តែ បើយោងតាមបញ្ញត្តិនៃមាត្រា៣ ចំណុច គ នៃអនុក្រឹត្យលេខ ៥០៥ អនក្រ.តត ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវី នៃគណៈមេធាវីនៃព្រះរាជាចក្រកម្ពុជា ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១ បានបញ្ជាក់យ៉ាងច្បាស់ថា កិច្ចការនេះត្រូវពិនិត្យ អានឲ្យអស់សេចក្តី និងចុះហត្ថលេខានៃគូភាគីនៅចំពោះមុខភាគី ទើបមេធាវីសារការីចុះហត្ថលេខា **ប្រថាប់ត្រា** ចារឹកនាពេលនោះជាចុងក្រោយ។ ដូច្នេះ **ត្រា**[៦២] មានសារៈសំខាន់សម្រាប់បញ្ជាក់ពីមុខមន្ទីររបស់ខ្លួន ហើយសារការីគួរតែមានត្រាបោះលើកិច្ចការគតិយុត្ត ដែលច្បាប់បានកំណត់ទុកឲ្យនោះបន្ទាប់ពីចុះហត្ថលេខាហើយ។

**អំពីតារាងតម្លៃប្រថាប់ត្រា**

តាមធម្មតាប្រាក់កម្រៃ ឬប្រាក់ឈ្នួលរបស់សារការី ត្រូវអនុញ្ញាតឲ្យយកពីអតិថិជនតាមព្រះរាជក្រឹត្យ ដោយអត្រាពីខ្ពស់ទៅទាប (Taux régressif)[៦៣]។

[៦២] យោងតាមវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត បានឲ្យនិយមន័យ **ត្រា** ថា គឺជាប្រដាប់មានស្នាមចម្លាក់ជាគ្រឿងសម្គាល់សម្រាប់សម្គាល់លើសំបុត្រ ចុតហ្មាយ ដីការ បញ្ជី សំបុត្រសន្យាផ្សេងៗតាមមុខងារ មុខក្រសួងបោះត្រា។

[៦៣] អាំង អេងថុង វិជ្ជាជីវៈសារការីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១២ ទំព័រ ទី ២៨។

ឧទាហរណ៍ តារាងតម្លៃប្រាក់កំរៃ ឬប្រាក់ឈ្នួលរបស់មេធាវីសារការី ប៉ែនសុន សម័យ ប្រថាប់ត្រា ធ្វើលេខាធារិកសារការី ការបញ្ជាំ ចងការ ជួល លក់អចលនវត្ថុ(ពុំមែនជាព្រះរាជក្រឹត្យ)

| | |
|---|---|
| ពី ០ ដល់ ១០.០០០.០០០ រៀល | ៣,៣៣% |
| ពី ១០.០០០.០០១ ដល់ ២០.០០០.០០០រៀល | ២,២% |
| ពី ២០.០០០.០០១ ដល់ ៥០.០០០.០០០រៀល | ១,១% |
| ពី ៥០.០០០.០០១ ដល់ ៥០០.០០០.០០០រៀល | ០,៨០% |
| ពី៥០០.០០០.០០០រៀលឡើងទៅ | ០,៥៥% |

រហូតមកដល់ពេលនេះ រាជរដ្ឋាភិបាលបានបង្កើតជាហូរហែរ នៅសាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ បានធ្វើការតែងតាំងមេធាវីសារការី ជាដើម ក៏ដោយក៏សារការីពុំទាន់មានលក្ខន្តិកៈក្របខណ្ឌនៅឡើយដែរ។

## ២.២ ការមិនអាចអនុវត្តបាននៃមុខងារសារការី

បើទោះបីជា មានបទប្បញ្ញត្តិគតិយុត្តជាច្រើនបាន ផ្តល់សមត្ថកិច្ចដល់សារការីក្នុងការផ្តល់យថាភូត ដូចជាការផ្ទេរកម្មសិទ្ធិអចលនវត្ថុ ការបញ្ជាំអចលនវត្ថុ និងលិខិតកិច្ចសន្យានានាមួយ-ចំនួនទៀត ដើម្បីយកមកប្រើប្រាស់តាមផ្លូវច្បាប់ក៏ដោយ ក៏យើងសង្កេតឃើញថាក្នុងការអនុវត្តជាក់ស្តែងនាពេលបច្ចុប្បន្ននេះ មុខងារក្នុងការផ្តល់យថាភូតភាពរបស់សារការីមិនត្រូវទាន់បាន គេយកមកអនុវត្ត ឲ្យមានប្រសិទ្ធិភាពនៅឡើយនោះទេ។ ឧទាហរណ៍ជាក់ស្តែង ដូចជាការចុះបញ្ជីផ្ទេរកម្មសិទ្ធិ ជាដើម។ យើងឃើញថា ភាពមិនអាចអនុវត្តបាននូវមុខងាររបស់សារការីនេះ គឺបណ្តាលមកពីបញ្ហាចំរូងចំរាស់ជាច្រើនទាំងលើបទប្បញ្ញត្តិច្បាប់ និងទាំងការអនុវត្តជាក់ស្តែង ។

លើសពីនេះទៅទៀត ទោះបីជាសញ្ញាណនៃមុខងារសារការី ត្រូវបានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩៦៧ រហូតដល់ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ និង ព្រមទាំងមានអនុក្រឹត្យតែងតាំងសារការីក៏ដោយ ក៏យើងឃើញថាវិជ្ជាជីវៈនេះ មិនត្រូវបានធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយ ដើម្បីឲ្យសារធារណៈជនបានយល់ដឹងនោះទេ ហើយវានៅតែជាវិជ្ជាជីវៈមួយដ៏ថ្មីស្រឡាងនៅឡើយសម្រាប់ប្រជាជនទូទៅ ជាពិសេសសូម្បីតែមន្ត្រីអនុវត្តមួយចំនួនធំ ក៏មិនបានយល់ច្បាស់អំពីមុខងារសារការីនេះដែរ ជាងនេះទៅទៀតនោះពួគាត់ពុំបានដឹងទេថាសារការីជាអ្នកណាតែម្តង។

តើមានបទប្បញ្ញត្តិអ្វីខ្លះដែលបានចែង ក្នុងការផ្តល់សមត្ថកិច្ចឲ្យមន្ត្រីដទៃទៀតក្នុងការធ្វើលិខិតយថាភូតទៀតនោះ (**២.២.១ ការបែងចែកមិនច្បាស់លាស់ជាមួយមន្ត្រីអនុវត្តផ្សេងទៀត**)?

តើនៅក្នុងការអនុវត្តជាក់ស្តែងមានបញ្ហាអ្វីខ្លះ ដែលធ្វើឲ្យសារការីមិនអាចអនុវត្តមុខងាររបស់ខ្លួន (**២.២.២ ការអនុវត្តជាក់ស្តែង**) ?

### ២.២.១ ការបែងចែកមិនច្បាស់លាស់ជាមួយមន្ត្រីអនុវត្តផ្សេងទៀត

ការបែងចែងសមត្ថកិច្ចមិនបានច្បាស់លាស់រវាង សារការីនិងមន្ត្រីផ្សេងៗទៀត គឺជាបញ្ហាប្រឈមមួយក្នុងការអនុវត្តមុខងាររបស់សារការី ជាក់ស្តែងដើម្បីអនុវត្តក្ររដ្ឋប្បវេណីឆ្នាំ២០០៧ គេ-បានបង្កើត ច្បាប់ស្តីពីអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ ដែលនៅក្នុងច្បាប់នោះមាត្រា៩ ចំណុច ខ បានប្រគល់សមត្ថកិច្ចទៅឲ្យមន្ត្រី ដែលមានសមត្ថកិច្ចក្នុងការចុះបញ្ជី បើយើងនិយាយឲ្យងាយយល់ទៅ គឺមន្ត្រីសុរិយោដីដែលវាផ្ទុយទៅ និងនិយមន័យនៃលិខិតយថាភូត នៅក្នុងសទ្ទានុក្រមរដ្ឋ-ប្បវេណី ដែលបានឲ្យសមត្ថកិច្ចក្នុងការធ្វើលិខិតយថាភូតទៅឲ្យមន្ត្រីសាធារណៈ ពោលគឺសារការីតែម្តងក្នុងការធ្វើលិខិតយថាភូតនេះ។

ដោយសារការមិនអាចអនុវត្តនៅមុខងារសារការី មានការពាក់ព័ន្ធជាមួយមន្ត្រីនៃការចុះបញ្ជីដូច្នេះ យើងសូមលើករដ្ឋបាលសុរិយោដីមកបកស្រាយនៅក្នុងចំណុចខាងក្រោមនេះ។

#### ២.២.១.១ រដ្ឋបាលសុរិយោដី

យោងតាមអនុក្រឹត្យលេខ ៦២ អនក្រ.បក ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបណីយកម្ម និងសំណង់ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ យើងនឹងពិនិត្យអំពីរចនាស-ម្ព័ន្ធគ្រប់គ្រងរបស់ក្រសួងនេះ ដោយធ្វើការស្វែងយល់ជាពិសេស ទៅលើអគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រ ដែលជានាយកដ្ឋនជិតស្និតបំផុតនិងការចេញប័ណ្ណកម្មសិទ្ធិដីធ្លី។

អគ្គនាយកដ្ឋាននេះ មានភារកិច្ចជាសេនាធិការ ឲ្យក្រសួងក្នុងការងារមួយចំនួន ដូចខាងក្រោមនេះ៖

- ជាសេនាធិការរបស់ក្រសួងរៀបចំដែនដី នគរូបណីយកម្ម និងសំណង់លើកិច្ចការសុរិយោដី និងភូមិសាស្ត្រ
- សិក្សាស្រាវជ្រាវ ឯកសាងគំរោងលិខិតបទដ្ឋានទាំងឡាយដែលពាក់ព័ន្ធ និងការងារគ្រប់គ្រង នឹងប្រើប្រាស់ដីធ្លី
- ចេញប័ណ្ណសម្គាល់សិទ្ធិដីធ្លីទូទាំងព្រះរាជាណាចក្រកម្ពុជា
- ធ្វើការងារអភិរក្សសុរិយោដី និងធ្វើអធិការកិច្ចក្នុងតួនាទីភារកិច្ច និងសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

- សហាការជាមួយក្រសួង និងស្ថាប័ននានាក្នុងការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី[៥៤]។ល។

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ មាននាយកដ្ឋានចំណុះចំនួនប្រាំ គឺ៖

- នាយកដ្ឋានគ្រប់គ្រង់ដីធ្លី
- នាយកដ្ឋានអធិការកិច្ចភូមិបាល
- នាយកដ្ឋានបច្ចេកទេស
- នាយកដ្ឋានអភិរក្សសុរិយោដី និង
- នាយកដ្ឋានភូមិសាស្ត្រ។

ក្នុងចំណោមនាយកដ្ឋានទាំងប្រាំខាងលើនេះ គឺមាននាយកដ្ឋានមួយប៉ុណ្ណោះ ដែលមានភាពជិតស្និតនឹងសំណុំលិខិតឯកសារផ្ទេរកម្មសិទ្ធ គឺនាយកដ្ឋានសុរិយោដី។ នាយកដ្ឋាននេះ មានតួនាទីនិងភារកិច្ចដូចតទៅ[៥៥]៖

- កាន់កាប់និងគ្រប់គ្រងឯកសារសុរិយោដី
- **ពិនិត្យ ផ្ទៀងផ្ទាត់ សំណុំលិខិតសញ្ញាផ្សេងៗ ដែលពាក់ព័ន្ធនឹងអចលនវត្ថុ**
- ធ្វើការអភិរក្សទ្រព្យសម្បត្តិរដ្ឋ
- **ចុះបញ្ជីដីធ្លី ធ្វើលេខាចារឹក និងចរន្តការ** រាល់ការវិវត្តអំពីលក្ខណៈរូប និងគតិយុត្ត
- រក្សាឯកសារ និងប័ណ្ណសារដ្ឋានភូមិបាល និង
- ផ្តល់ពតិមានដីធ្លី។

ឆ្លងតាមរយៈការបកស្រាយខាងលើនេះ យើងឃើញថា មុខងាររបស់រដ្ឋបាលសុរិយោដី គឺគ្រាន់តែធ្វើការពិនិត្យ ផ្ទៀងផ្ទាត់ឯកសារដែលទាក់ទង នឹងការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ ចុះបញ្ជី ផ្ទេរកម្មសិទ្ធិលើដីធ្លី ធ្វើលេខាចារឹក និងចរន្តការចំពោះលក្ខណៈនៃអចលនវត្ថុតែប៉ុណ្ណោះ។ ត្រង់នេះសរបញ្ជាក់ឲ្យយើងឃើញថា មុខងារសំខាន់របស់រដ្ឋបាលសុរិយោដី គឺធ្វើការចុះបញ្ជីដីធ្លីនិងផ្ទៀងផ្ទាត់លើលិខិតគតិយុត្ត ហើយរដ្ឋបាលនេះមិនមានមុខងារក្នុងការចេញសេចក្តីបញ្ជាក់ អះអាងទាក់ទងនឹងលិខិតគតិយុត្ត ដែលមានកម្មវត្ថុផ្ទេរកម្មសិទ្ធិលើអចលនវត្ថុនោះទេ។

[៥៤] មាត្រា ២១ នៃអនុក្រឹត្យលេខ ៦២ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបណីយកម្ម និងសំណង់ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩

[៥៥] មាត្រា ២៦ នៃអនុក្រឹត្យលេខ ៦២ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបណីយកម្ម និងសំណង់ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩

### ២.២.១.២ រដ្ឋបាលមូលដ្ឋាន

នៅក្នុងការអនុវត្តជាក់ស្តែង យើងសង្កេតឃើញថា អាជ្ញាធរមូលដ្ឋាន ឬហៅថារដ្ឋបាលមូលដ្ឋានមេឃុំ/ចៅសង្កាត់ អភិបាលស្រុក/ខណ្ឌ បានដើរតួនាទីយ៉ាងសកម្មនៅក្នុងការចេញលិខិតបញ្ជាក់ផ្សេងៗទាក់ទងនិងអចលនវត្ថុ។ ប៉ុន្តែយើងមានចម្ងល់មួយដែលបានផុសឡើងថា តើអាជ្ញាធរមូលដ្ឋានដែលអនុវត្តមុខងារនេះ? ផ្អែកលើបទដ្ឋានគតិយុត្តអ្វីជាសំអាង?

តាមរយៈការស្រាវជ្រាវរបស់ខ្ញុំមុនឆ្នាំ២០០៥ ពុំមានលិខិតបទដ្ឋានគតិយុត្តណាជាផ្លូវការ ក្នុងការផ្តល់សិទ្ធិឲ្យអាជ្ញាធរមូលដ្ឋាន អនុវត្តមុខងារចេញលិខិតបញ្ជាក់កិច្ចសន្យានានា ទាក់ទងនឹងការទិញលក់អចលនវត្ថុ និងការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុនោះទេ។ ដោយហេតុថា ពុំមានអាជ្ញាធរណាដែលអាចដឹងពីសាវតា និងប្រវត្តិនៃការកាន់កាប់ដី នឹងដឹងអំពីអត្តសញ្ញាណច្បាស់លាស់របស់អ្នកគ្រប់គ្រងដីជាងអាជ្ញាធរមូលដ្ឋាននេះ ហេតុនេះហើយអាជ្ញាធរមូលដ្ឋានក៏បានអនុវត្តមុខងារខាងលើនេះតែម្តងទៅ ដោយពុំមានការជំទាស់ពីស្ថាប័នណាឡើយ។

លុះមកដល់ឆ្នាំ២០០៥ ក្រសួងមហាផ្ទៃនិងក្រសួងរៀបចំដែនដី នគរូបនីកម្ម និងសំណង់ បានធ្វើការប្រជុំពិភាក្សាគ្នាអំពីកិច្ចការខាងលើនេះ ជាលទ្ធផលក្រសួងទាំងពីរក៏បានឯកភាពគ្នាចេញប្រកាសរួមមួយលេខ ២១៥ ប្រក/ជនស.មជ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ/សង្កាត់ ក្នុងការចុះបញ្ជីដីធ្លី។

តាមរយៈប្រកាសអន្តរក្រសួងខាងលើនេះ រដ្ឋាភិបាលបានធ្វើប្រតិភូកម្មអំណាច ដល់ក្រុមប្រឹក្សា ឃុំ/សង្កាត់ ឲ្យបំពេញភារកិច្ចចូលរួមក្នុងប្រតិបត្តិការចុះបញ្ជីដីធ្លីក្នុងមូលដ្ឋានរបស់ខ្លួន[៣១] ។ក្រុមប្រឹក្សាឃុំ/សង្កាត់ ត្រូវធ្វើប្រតិភូកម្មបន្តដល់មេឃុំ/ចៅសង្កាត់ ក្នុងការចូលរួមធ្វើប្រតិបត្តិការចុះបញ្ជីដីធ្លី សំដៅធានាការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋ ធានាការពារសិទ្ធិកម្មសិទ្ធិនិង សិទ្ធិផ្សេងៗទៀតលើអចលនវត្ថុ[៣៣]។

មាត្រា៨ នៃប្រកាសដដែលនេះ បានចែងស្រដៀងនឹងមាត្រា៦៥ នៃច្បាប់ភូមិបាលថា៖

" ដើម្បីឲ្យការផ្ទេរកម្មសិទ្ធិ មិនអាចជំទាស់ពីតតិយជនបានកិច្ចស្យានោះត្រូវជាលាយលក្ខណ៍-អក្សរ តាមទម្រង់លិខិតយថាភូតដោយអាជ្ញាធរមានសមត្ថកិច្ច ហើយត្រូវបានចុះបញ្ជីនៅអង្គភាពសុរិយោដី"។

---

[៣១] មាត្រា១ នៃប្រកាសអន្តរក្រសួងលេខ ២១៥ ប្រក/ជនស.មជ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០០៥

[៣៣] មាត្រា១ និង មាត្រា២នៃប្រកាសអន្តរក្រសួងលេខ ២១៥ ប្រក/ជនស.មជ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០០៥

មាត្រា៨នេះ គ្រាន់តែជាលក្ខខណ្ឌនៃការផ្ទេរកម្មសិទ្ធិដែលត្រូវឲ្យធ្វើជា ទម្រង់លិខិតយថាភូត ដោយអាជ្ញាធរមានសមត្ថកិច្ច ហើយមិនបានចែងទេថានរណាមានសមត្ថកិច្ចនោះទេ។ក៏ប៉ុន្តែ មាត្រាបន្ទាប់នៃប្រកាសនេះបានធ្វើការបញ្ជាក់ និងបង្ហាញអំពីអ្នកដែលមានសមត្ថកិច្ច ក្នុងការបញ្ជាក់លើលិខិតផ្ទេរកម្មសិទ្ធិទាំងឡាយដោយមាត្រា៩ បានចែងថា ៖

" **អភិបាលស្រុក ខណ្ឌ ឬមេឃុំ ចៅសង្កាត់ជាអ្នកបញ្ជាក់លិខិតសញ្ញាផ្សេងៗ** ដូចជា **លិខិតលក់ផ្ដាច់ អំណោយផ្ដាច់...** អាស្រ័យលើការព្រមព្រាងរបស់គូភាគី។ **ក្នុងការបញ្ជាក់** អភិបាលស្រុក ខណ្ឌ ឬមេឃុំ ចៅសង្កាត់ត្រូវយកចិត្តទុកដាក់ និងទទួលខុសត្រូវលើ៖

- អត្តសញ្ញាណអចលនវត្ថុ ដែលជាកម្មវត្ថុនៃលិខិតសន្យា និង
- អត្តសញ្ញាណគូភាគីនៃកិច្ចសន្យា" ។

មាត្រា៩ នេះបានស្តែងយ៉ាងច្បាស់ថា រដ្ឋបាលមូលដ្ឋានមានសមត្ថកិច្ចក្នុងការចេញសេចក្ដី-បញ្ជាក់លើកិច្ចសន្យាផ្ទេរកម្មសិទ្ធិនានា។ ថ្វីត្បិតតែរដ្ឋបាលនេះ ចេញជាសេចក្ដីបញ្ជាក់ដែលតាមបទប្បញ្ញត្តិច្បាប់ តម្រូវឲ្យមានជាលិខិតយថាភូត ទើបអាចធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិក៏ដោយ ក៏យើងសង្កេតឃើញថា សេចក្ដីបញ្ជាក់របស់រដ្ឋបាលនេះត្រូវបានយកទៅប្រើប្រាស់ ហើយវាមានតម្លៃគតិ-យុត្តអាចយកទៅធ្វើការចុះបញ្ជីបានទៀតផង ដែលយើងអាចធ្វើការសន្និដ្ឋានបានថា សេចក្ដីបញ្ជាក់របស់រដ្ឋបាលមូលដ្ឋាននេះ គឺត្រូវបានចាត់ទុកដូចជាការផ្ដល់យថាភូតភាពទៅលើកិច្ចសន្យាផ្ទេរកម្មសិទ្ធិផងដែរ។

បញ្ហាដែលបានលើកឡើងខាងលើនេះ គឺមកពីការខ្វះនៅបញ្ញត្តិមួយដ៏ជាក់លាក់ក្នុងការកំណត់នៅមុខងារ ក៏ដូចជាវិសាលភាពនៃមុខងារសារការី ។ ជាពិសេសនោះ គឺអវត្តមាននៃច្បាប់ស្ដីពីលក្ខ-ន្តិកៈសារការីតែម្ដង ដែលក្នុងពេលបច្ចុប្បន្ននេះ វានៅតែជាសេចក្ដីព្រាងច្បាប់តែប៉ុណ្ណោះ។ នេះគឺជាបញ្ហាទាក់ទង និងបញ្ហាគតិយុត្តដែលធ្វើឲ្យវិជ្ជាជីវៈសារការីពុំអាចអនុវត្តទៅបាន។

### ២.២.២ ការអនុវត្តជាក់ស្តែង

បើទោះបីជាយើងដឹងថា មុខងារសារការី ជាមុខងារដ៏សំខាន់មួយក្នុងចំណោម មុខងារសំខាន់ៗដទៃទៀតក្នុងវិស័យច្បាប់ក៏ដោយ ក៏យើងសង្កេតឃើញថាមុខងារនេះ ពុំត្រូវបានគេអនុវត្តនុឲ្យបានមានប្រសិទ្ធិភាពនៅឡើយទេ។ តើនៅពេលបច្ចុប្បន្ននេះមានកត្តាអ្វីខ្លះក្រៅពីបញ្ហា ដែលបានបកស្រាយខាងលើទាក់ទងនឹង បទដ្ឋានគតិយុត្តនោះទៀត ក្នុងការដែលធ្វើឲ្យការអនុវត្តមុខងារសារការីនេះពុំអាចទទួលបានប្រសិទ្ធិភាពនោះ?

### ២.២.២.១ ទំហំនៃការងាររបស់សារការី

វិសាលភាពនៃមុខងារយ៉ាងច្រើន ដែលបានបញ្ញត្តិនៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ ក៏ដូចជា ក្រមរដ្ឋវេណីឆ្នាំ២០០៧ បានធ្វើឲ្យសារការីទទួលរ៉ាប់រងនៅទំហំការងារជាច្រើន ដែលច្បាប់បាន ប្រគល់ទៅឲ្យហើយដែលជាចាំបាច់ គឺតម្រូវនូវវត្តមានរបស់សារការីជាច្រើន ដើម្បីអនុវត្តការងារ ទាំងអស់នោះ ប៉ុន្តែបើក្រឡេកមើលបរិបទនៃវិជ្ជាជីវៈសារការី នៃប្រទេសកម្ពុជាយើងនាពេល បច្ចុប្បន្ននេះវិញ គឺនៅមានចំនួនសារការីតិចតួចនៅឡើយ ។

### ២.២.២.២ ការផ្សព្វផ្សាយ

ដូចធ្លាប់បានលើកឡើងខ្លះៗរួចមកហើយ ក្នុងការបកស្រាយខាងលើនោះ យើងឃើញថា ទោះបីជាសញ្ញាណរបស់សារការី ត្រូវបានបញ្ញត្តិតាំងពីក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩៦៧ រហូតដល់ ក្រមរដ្ឋប្បវេណី២០០៧ ហើយក៏ថែមទាំងមានការប្រលងប្រជែង ដើម្បីទទួលបានការបណ្តុះបណ្តា-លវិជ្ជាជីវៈសារការីនេះនាឆ្នាំកន្លងទៅនេះក៏ដោយ ក៏យើងឃើញថាវិជ្ជាជីវៈសារការីនេះ មិនត្រូវបាន ផ្សព្វផ្សាយឲ្យបានទូលំទូលាយ ដើម្បីឲ្យសាធារណៈជនបានយល់ដឹងច្បាស់នោះទេ ហើយវាក៏នៅ តែជាវិជ្ជាជីវៈមួយ ដ៏ថ្មីស្រឡាងនៅឡើយសម្រាប់ប្រជាជន ជាពិសេសទៅទៀតនោះសូម្បីតែមន្ត្រី អនុវត្តមួយចំនួនធំ ក៏មិនបានយល់ច្បាស់ អំពីមុខងារសារការីនេះដែរ ជាងនេះទៅទៀតគឺពួកគាត់ពុំ បានដឹងទេថា តើសារការីជានរណាតែម្តង។

### ២.២.២.៣ ការមិនអាចអនុវត្តបាននៃលិខិតរបស់សារការី

យើងឃើញថា បើទោះបីជាមានបទប្បញ្ញត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៣៥០ , ៤៩៦ មាត្រា៨ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ និងមាត្រាជាច្រើនទៀតបានចែងអំពី អានុភាពអនុវត្តដោយបង្ខំ នៃលិខិតរបស់សារការីក៏ដោយ ក៏យើងសង្កេតឃើញថាការអនុវត្តនៃ លិខិតរបស់សារការីនៅក្នុងពេលបចុប្បន្ននេះ ពុំត្រូវបានស្ថាប័នអនុវត្តយកមកប្រើប្រាស់ ឲ្យមាន ប្រសិទ្ធិភាពនៅឡើយនោះទេ។ នេះគឺជាបញ្ហាមួយដែលច្បាប់ ដែលផ្តល់អានុភាពទៅដល់លិខិត របស់សារការី កំពុងតែនៅជាធរមាននៅឡើយតែបែជាមិនអាចយកទៅអនុវត្តបានទៅវិញ។

### ២.២.២.៤ តម្លៃសេវារបស់សារការី

យើងសង្កេតឃើញថា តម្លៃសេវាដែលសារការីទទួលដើម្បីបម្រើដល់អតិថិជនក្នុងការធ្វើ លិខិត អ្វីមួយនោះនៅមានតម្លៃខ្ពស់ បើប្រៀបធៀបទៅនឹងតម្លៃសេវានៃវិជ្ជាជីវៈសេរីដ៏ទៃទៀត ជាក់ស្តែង ដូចជាវិជ្ជាជីវៈមេធាវី ជាដើម ដែលយើងតែងតែងសង្កេតឃើញថា នៅពេលដែលអតិថិជនគាត់មាន

បំណងចង់ធ្វើកិច្ចសន្យាអ្វីមួយនោះ គេតែងតែទៅរកមេធាវីដើម្បីពឹងពាក់។ មួយវិញទៀត យើងកម្រឃើញអ្នកដែលមានជីវភាពធម្មតាទៅ ពឹងពាក់សារការីឲ្យបង្កើតកិច្ចសន្យាឲ្យណាស់ គឺមានតែអ្នកដែលមានធនធានសមរម្យទេដែលតែងតែទៅសេវាសារការី។

# សេចក្តីសន្និដ្ឋាន

ដោយយោងតាមការបកស្រាយកមកខាងលើនេះ យើងឃើញថាវិជ្ជាជីវៈសារការីនៃប្រទេសកម្ពុជាយើងមានកំណើតតាំងពីរយូរយារមកហើយ ពោលគឺមានតាំងពីរមុនមានក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩៦៧ មកម្លេះ។ សារការី គឺជាមន្ត្រីសាធារណៈដែលទទួលបានប្រតិភូកម្មអំណាចពីរាជរដ្ឋាភិបាលដែលមានតួនាទីយ៉ាងសកម្ម និង សំខាន់ក្នុងការតាក់តែងលិខិតគតិយុត្តដោយសារការីបានផ្តល់ការពិគ្រោះយោបល់ និងបញ្ជាក់នូវបំណងពិតរបស់គូភាគីទាំងសងខាង ពីដើមដំបូងហើយ និងពន្យល់ហេតុផលទាំងនោះ ។

យើងឃើញថា មានបញ្ញត្តិជាច្រើនដែលបានកំណត់ ពីមុខងារ របស់សារការី ដូចជា ព្រះរាជក្រម ៩១០ នស.ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ ១៩៥៤ / អនុក្រឹត្យ ៥០៥ អនក្រ.តត ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ ២០០១/ អនុក្រឹត្យ ១៩៤ អនក្រ បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៨ និងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។ បើទោះបីជាមានការវិវត្តជាច្រើនក៏ដោយ មុខងារសំខាន់របស់សារការីគឺធ្វើលិខិតយថាភូត និងបង្កើតកិច្ចសន្យាទាំងឡាយដែលច្បាប់ទាំងឡាយបានប្រគល់ឲ្យ ដើម្បីឲ្យកិច្ចសន្យា និងលិខិតទាំងនោះមានអានុភាពតាមផ្លូវច្បាប់។

សារការី គឺជាមន្ត្រីសាធារណៈដែលអនុវត្តវិជ្ជាជីវៈសេរី ដែលមានសេរីភាពក្នុងការទទួលយកអតិថិជនដើម្បីបំរើសេវារបស់ខ្លួន។ ហើយបើយើងប្រៀបធៀបទៅនឹងវីជ្ជាជីវៈសេរីផ្សេងទៀត ដូចជាមេធាវី វាមានលក្ខណៈប្រហាក់ប្រហែលគ្នា ។ ប៉ុន្តែអ្វីដែលវិជ្ជាជីវៈសារការីនេះមានភាពខុសគ្នា ទៅនឹងវិជ្ជាជីវៈសេរីដ៏ទៃនោះ គឺលិខិតរបស់សារការីជាលិខិតដែលមានចុះ(ថ្ងៃ ខែ ឆ្នាំ) និងមានយថាភាពតាំងពីបានបង្កើតលិខិតនោះ ជាងនេះទៅទៀតលិខិតរបស់សារការី គឺមានអានុភាពអនុវត្តដោយបង្ខំ ដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីរបស់តុលាការ ដើម្បីសុំការអនុវត្តនោះទេ ចំណែក

លិខិតដែលធ្វើឡើងដោយមេធាវី ដើម្បីឲ្យមានអានុភាពអនុវត្ត គឺចាំបាច់ត្រូវឆ្លងកាត់នីតិវិធីតុលាការ ពីព្រោះលិខិតដែលធ្វើឡើងដោយមេធាវី គឺក្នុងនាមជាសាក្សីដែលបានដឹងលឺតែនៅពេលបង្កើតលិខិតនោះតែប៉ុណ្ណោះ។ ដូចនេះលិខិតទាំងឡាយណា ដែលអតិថិជនចង់បាននៅភាពច្បាស់លាស់ និងក្លាយជាលិខិតសាធារណៈ(លិខិតយថាភូត)នោះ គឺចាំបាច់ត្រូវធ្វើនៅមុខមន្ទីសារការី។ ដូច្នេះ យើងសង្កេតឃើញថា ការទទួសខុសរបស់សារការី និងមេធាវីមានលក្ខណៈខុសគ្នា ហើយវិជ្ជាជីវៈសារការីនឹង វិជ្ជាជីវៈមេធាវីគឺមានវិសមិតភាពនិងគ្នា ។ ប៉ុន្តែបើយោងតាមអនុក្រឹត្យលេខ ៥០៥ អនុ-ក្រឹត្យ.តត ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១ យើងឃើញថា អនុក្រឹត្យនេះបានផ្តល់មុខងារបន្ថែមជាសារការីដល់មេធាវី នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នេះមកពីភាពចាំបាច់នៃតម្រូវការនៃមុខងារសារការីក្នុងពេលបច្ចុប្បន្នដែល តម្រូវឲ្យមានអ្នកមានតួនាទីសារការីបន្ថែម។ ការតែងតាំងមន្ត្រីទទួលបន្ទុកសារការី ដែលជាមន្ត្រីទទួលមុខងារឲ្យអនុវត្តមុខងារសាធារណៈនោះទៅទៀត ដែលជាទូទៅមុខងារសារការីមានវិសមិតភាព ជាមួយមន្ត្រីទទួលមុខងារសាធារណៈផងដែរ។

ដូច្នេះយើងឃើញថា វិជ្ជាជីវៈសារការីគឺមានសារៈសំខាន់ណាស់ ក្នុងការរក្សាសណ្តាប់ធ្នាប់ និងស្ថេរភាពក្នុងសង្គម ពីព្រោះបើយើងពិនិត្យទៅលើមុខងាររបស់សារការីគឺមានភាពរឹងមាំក្នុងការពង្រឹងស្ថានភាពគតិយុត្តទាក់ទងនឹង កិច្ចសន្យាជាច្រើនដែលច្បាប់បានប្រគល់ឲ្យវិជ្ជាជីវៈមួយនេះ។

ការសិក្សាអំពីមុខងារនៃវីជ្ជាជីវៈសារការី តែមួយមុខនៅក្នុងប្រធានបទសារណារបស់ខ្ញុំនេះ គឺវាមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនោះទេ ដូច្នេះវាទាមទារឲ្យអ្នកសិក្សាស្រាវជ្រាវ សិក្សាឲ្យបានស៊ីជម្រៅទៅលើកត្តាមួយចំនួនទៀតដូចជា សញ្ញាណនៃលិខិតយថាភូត នីតិវិធីនៃការប្តឹងជំទាស់ លិខិតសារការី ឬនីតិវិធីអនុវត្តដោយបង្ខំនៃលិខិតយថាភូតរបស់សារការីបន្ថែមទៀត។ល។ យើងមើលឃើញថា ទោះបីជាមានបញ្ញត្តិចែងអំពីនីតិវិធីអនុវត្តដោយបង្ខំ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ ក៏នៅក្នុងការអនុវត្តជាក់ស្តែងនាពេលបច្ចុប្បន្ននេះ នៅពុំទាន់មានប្រសិទ្ធិភាពនៅឡើយ។ ហេតុដូច្នេះ វាតម្រូវឲ្យអ្នកសិក្សាស្រាវជ្រាវសិក្សាចំនុចទាំងនេះ ឲ្យបានស៊ីជម្រៅបន្ថែមទៀតពីលើប្រធានបទសារណៈរបស់ខ្ញុំបាទ ដើម្បីបង្កើននៅភាពច្បាស់លាស់ទៅលើចំណុចនីមួយៗ ដែលពាក់ព័ន្ធទៅនឹងមុខងាររបស់សារការី។

# អនុសាសន៍

មុខងារសារការី គឺពិតជាមានតួនាទីសំខាន់ណាស់ ក្នុងការចូលរួមចំណែកថែរក្សាស្ថេរភាពគតិយុត្ត ក៏ដូចជាស្ថេរភាពក្នុងសង្គមកម្ពុជា ពីព្រោះមុខងារនេះបានបញ្ចៀសបញ្ហាជាច្រើន ក្នុងទំនាក់ទំនងរបស់សង្គមមនុស្សប្រចាំថ្ងៃ។ ដូច្នេះដើម្បីឲ្យវិជ្ជាជីវៈសារការីនេះ មានដំណើរការទៅបានដោយរលូននៅក្នុងប្រទេសកម្ពុជាយើង ខ្ញុំបាទសូមបញ្ចេញនៅយោបល់មួយចំនួនទៀតដើម្បីធ្វើឲ្យវិជ្ជាជីវៈនេះ មានដំណើរការកាន់តែល្អជាងពេលបច្ចុប្បន្ននេះដូចខាងក្រោម៖

- ដោយសារវិជ្ជាជីវៈសារការី ជាវិជ្ជាជីវៈដែលកម្រនឹងមានអ្នកដឹងនៅក្នុងការអនុវត្ត នាពេលបច្ចុប្បន្ននេះក្រៅតែពីអ្នកជំនួញ នឹងអ្នកដែលអនុវត្តការងារនេះតែម្តង ដូច្នេះ ស្ថាប័នដែលពាក់ព័ន្ធនៅក្នុងវិស័យនេះគួរតែ បង្កើនការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍របស់មុខងារនេះទៅដល់ប្រជាជនទូទៅ សិស្ស និស្សិត និង មន្ត្រីដែលអនុវត្ត តាមរយៈការធ្វើជាសិក្ខាសាលាតាមបណ្តាសាលា ខេត្ត ឬក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធនៅក្នុងការអនុវត្ត និងធ្វើការផ្សព្វផ្សាយតាមរយៈបណ្តាយសង្គមផ្សេងៗជាដើម។
- បង្កើនការបណ្តុះបណ្តាលសារការីបន្ថែមទៀត ពីព្រោះក្នុងពេលបច្ចុប្បន្នសារការីដែលកំពុងអនុវត្តមុខងារក្នុងប្រទេសកម្ពុជា នៅមានចំនួនតិចតួចនៅឡើយបើប្រៀបទៅនឹងបណ្តាលប្រទេសក្នុងតំបន់ ពោលគឺ មានចំនួនតែ បីនាក់ ប៉ុណ្ណោះ លើសពីនេះទៅទៀតសារការីម្នាក់ជាមេធាវី ដែលបន្ថែមមុខងារសារការីទៅទៀ រីឯចំនួនសិស្សសារការីដែលកំពុងតែបណ្តុះបណ្តាលមានតែ១៥ នាក់ប៉ុណ្ណោះ ដែលចំនួននេះពិតជានៅតិចណាស់។
- តាក់តែងបទដ្ឋានគតិយុត្តដើម្បីគ្រប់គ្រង និងបង្កើតឲ្យមានរចនាសម្ព័ន្ធសារការីមួយឲ្យបានច្បាប់លាស់ ជាពិសេស គឺពន្លឿនការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈសារការី ដែលបច្ចុប្បន្ននេះវានៅតែជាសេចក្តីព្រាងច្បាប់នៅឡើយ ពីព្រោះច្បាប់នេះគឺមានសារៈសំខាន់ណាស់ក្នុងការកំណត់មុខងាររបស់សារការី និងមន្ត្រីដទៃផ្សេងទៀត ក៏ដូចជា រៀបចំឲ្យមាន

រចនាសម្ព័ន្ធនៃវិជ្ជាជីវៈសារការីនេះឲ្យបានជាក់លាក់។ ជាងនេះទៅទៀត រាល់សារការីរួមទាំងមន្ត្រីនៃសេវាសារការីទាំងអស់ ដែលកំពុងតែអនុវត្តមុខងារនេះក្នុងពេលបច្ចុប្បន្ន ត្រូវខិតខំបំពេញភារកិច្ចរបស់ខ្លួនឲ្យបានល្អ គោរពច្បាប់និងលាក់បាំងជារៀងរហូតចំពោះរឿងដែលខ្លួនទទួលបន្ទុក ដើម្បីផ្តល់ទំនុកចិត្តដល់អតិថិជនដែលកំពុងប្រើសេវាកម្មនេះ ជា-ពិសេសគឺអតិថិជនដែលកំពុងសម្លឹង រកសេវាកម្មណាមួយដែលគេអាចធ្វើឲ្យគេទុកចិត្ត ក្នុងការរក្សាការសម្ងាត់ចំពោះកិច្ចសន្យា ឬអាចធ្វើឲ្យកិច្ចសន្យារបស់គេមានសុពលភាពយ៉ាងពេញទម្រង់ច្បាប់ ។

- មុននឹងប្រថាប់ត្រាលើឯកសារអ្វីមួយ សេវាសារការីត្រូវត្រួតពិនិត្យខ្លឹមសារឲ្យបានច្បាស់លាស់ ឬ ចាត់ឲ្យស៊ើបអង្កេតឲ្យបានហ្មត់ចត់ ដើម្បីធានាថាឯកសារនោះត្រឹមត្រូវតាមច្បាប់អាចយកជាការបាន ព្រោះវិធានការរក្សាសុវត្ថិភាពទាំងនេះ នឹងអាចជៀសវៀងបាននូវការប្តឹងផ្តល់នៅស្ថាប័នតុលាការទៅថ្ងៃក្រោយ។ ខ្ញុំបាទលើកចំនុចនេះឡើង ក៏ព្រោះតែដោយសារបច្ចុប្បន្ននេះ យើងកំពុងជួបការលំបាកជាច្រើន ក្នុងការដោះស្រាយបញ្ហាទំនាស់រឿងកម្មសិទ្ធិដីធ្លីមួយចំនួន ដោយកន្លងមកការប្រថាប់ត្រាបញ្ជាក់ហត្ថលេខានានា ធ្វើមិនទាន់បានត្រឹមត្រូវតាមបទដ្ឋានកំណត់។
- សេវាសារការីត្រូវប្រកាន់ជំហរអព្យាក្រឹត្យ នៅពេលប្រថាប់ត្រាលើឯកសារណាមួយ ពោលគឺមិនត្រូវលំអៀងទៅលើភាគីណាមួយទេ។ សេវាសារការី ដើរតួជាអ្នកតំណាងនិងទទួលខុសត្រូវឲ្យដល់ភាគីទាំងសង្ខាង និងធ្វើអាជ្ញាកណ្តាលដើម្បីធានាឲ្យមានភាពត្រឹមត្រូវ តម្លា-ភាព និងយុត្តិធម៌ដល់អតិថិជន។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមអំពាវនាវដល់ស្ថាប័នដែលពាក់ព័ន្ធទាំងអស់ ដូចជា តំណាងនៃប្រព័ន្ធច្បាប់ តុលាការ ជាពិសេសគឺប្រជាពលរដ្ឋទាំងអស់សូមជួយអនុវត្ត ក៏ដូចជាជួយលើតម្កើងមុខងារសារការីនេះ ដើម្បីឲ្យមុខងារនេះចូលរួមចំនែកក្នុងការធានា តម្លាភាព និងយុត្តិធម៌ក្នុងសង្គមយើង។ ខ្ញុំបាទសូមឲ្យសិស្ស និស្សិត លោក លោកស្រី សាស្ត្រាចារ្យ ទាំងអស់ដែលបានកាន់សារ-ណាមួយនេះអាន មេត្តាជួយផ្សព្វផ្សាយ អំពីមុខងារសារការីឲ្យបានទូលំទូលាយ ក្នុងចំណោមសា-ធារណៈជនទាំងអស់ ជាពិសេសក្នុងចំណោមអ្នកជំនួញ វិនិយោគិន ដើម្បីឲ្យមុខងារសារការីនេះមានដំណើរការទៅប្រកបដោយប្រសិទ្ធិភាព ជៀសផុតពីការឆបោក គៃបន្លំ ទំនាស់ ឬបទល្មើសផ្សេងៗទៀតដែលអាចកើតមានឡើងជាយថាហេតុ។

ខ្ញុំសង្ឃឹមថា មុខងារសារការីនេះនឹងអាចអនុវត្តបានល្អ និងទទួលបានជោគជ័យក្នុងការបំពេញសកម្មភាពរបស់ខ្លួននាពេលអនាគត។

ខ្ញុំបាទ សូមអរគុណយ៉ាងជ្រាលជ្រៅ ចំពោះការយកចិត្តទុកដាក់ ក្នុងការអានសារណារបស់ខ្ញុំបាទតាំងពីដើមរហូតដល់ចប់។ ខ្ញុំសង្ឃឹថាសារណាមួយនេះ នឹងផ្តល់នៅចំណេះដឹងតិចតួចបន្ថែមទៀត ដល់អ្នកទាំងអស់គ្នាដែលបានអានសារណាមួយនេះ ដែលវាអាចបន្ថែមទៅលើចំណេះដឹងដែលមិត្តភក្តិបានដឹង នឹងបានយល់កន្លងមកហើយ។

# ឯកសារយោង

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- ក្រមរដ្ឋប្បវេណី ប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឲ្យប្រើនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦
- ក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩៦៧ របស់ លោក **អេង សុត**
- ច្បាប់ភូមិបាលឆ្នាំ១៩៩២ ដែលបានប្រកាសឲ្យប្រើ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩២
- ច្បាប់ភូមិបាល២០០១ ដែលបានប្រកាសឲ្យប្រើ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០១
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ប្រកាសឲ្យប្រើនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១
- ព្រះរាជក្រម លេខ ៩១០ នស.ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤
- អនុក្រឹត្យ ៥០៥ អនក្រ.តត ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការី ដល់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ ២០០១
- អនុក្រឹត្យ ១៤៥ អនក្រ .បក ស្តីពីការទទួលស្គាល់ មន្ទីសារការី អេច ប៊ី អេសនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៨
- អនុក្រឹត្យលេខ១៧៧ អនក្រ បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨ ជាអនុក្រឹត្យបង្កើតសាលាភូមិន្ទសារការី
- អនុក្រឹត្យលេខ ៦២ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងដែនដី នគរូបណីយកម្ម និងសំណង់ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩
- ប្រកាសលេខ៤៧ កយ.ប្រក/១២ ស្តីពីរការតែងតាំងមន្ត្រីទទួលបន្ទុកកិច្ចការសារការី ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១០១២
- ប្រកាសលេខ ៣២ កយ.ប្រក /១២ ស្តីពីការតែងតាំងមន្ត្រីទទួលបន្ទុកកិច្ចការសារការី ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២
- ប្រកាសអន្តរក្រសួងលេខ ២១៥ ប្រក/ ដនស.មជ ស្តីពី តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ ក្នុងការចុះបញ្ជីដីធ្លី
- សៀវភៅ មុខងារសារការីនៃព្រះរាជាណាចក្រកម្ពុជា របស់ លោក **អាំង អេងថុង** ឆ្នាំ២០១២ (បណ្ណាគារអង្គរធំ)
- សៀវភៅស្តីពី សន្និសិទស្តីពី មុខងារ សារការីតាមបែបប្រទេសបារាំង ថ្ងៃទី១៧-១៨ ខែកុម្ភៈ ឆ្នាំ២០០៤

- វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត
- វចនានុក្រ បារាំង-ខ្មែរ របស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

## គេហទំព័រដែលពាក់ព័ន្ធ

- Yp.com.kh/listings/kh16284-notary-of-the-cambodia
- Yp.com.kh/listings/kh29250-hbs-law-hbs-notary-puplic
- rajp.gov.kh

# បញ្ជីឧបសម្ព័ន្ធ

- ព្រះរាជក្រម លេខ ៩១០ នស.ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤
- អនុក្រឹត្យ ៥០៥ អនក្រ.តត ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការី ដល់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០១
- អនុក្រឹត្យ ១៩៤ អនក្រ .បក ស្តីពីការទទួលស្គាល់ មន្ទីសារការី អេច ប៊ី អេសនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៨
- ប្រកាសលេខ៩៧ កយ.ប្រក/១២ ស្តីពីរការតែងតាំងមន្ត្រីទទួលបន្ទុកកិច្ចការសារការី ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១០១២
- ប្រកាសលេខ ៣២ កយ.ប្រក /១២ ស្តីពីការតែងតាំងមន្ត្រីទទួលបន្ទុកកិច្ចការសារការី ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២
- ប្រកាសលេខ ១៧ ប្រក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការតែងតាំងសិស្សសារការីជំនាន់ទី១ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- គំរូលិខិតលក់ផ្តាច់
- គំរូលិខិតរបស់សារការី
- គំរូកិច្ចសន្យានានាទាក់ទងនឹងការផ្តល់យថាភូត